ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ ក្រុមហ៊ុន ជីបម៉ុង

# CHIP MONG CASH MANAGEMENT EFFICIENCY

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង

CHIP MONG CASH MANAGEMENT EFFICIENCY

គ្រូណែនាំ៖ វ៉ែន សុខលាង

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

វ៉ែន សុខលាង

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមនាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថា ជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរ សម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យ ហិរញ្ញវត្ថុ និងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍ការងារនៅក្នុងទីផ្សារផ្សេងៗជាច្រើនទៀត ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ក្រុមនាងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមនាងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី **"ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់យល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន។ ក្រុមនាងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះ និងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមនាងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមនាងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**សំណាង ស្រីវីន**
ID: B22/789



**ឡាង សុភា**
ID: B22/2265



**កែ ដាវី**
ID: B22/1165



**គង់ ម៉េងឃាង**
ID: B22/1201



**ជុន ស្រីភា**
ID: B22/1166

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិកានៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **វ៉ែន សុខលាង** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ..៨កើតខែ..កត្តិក..ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៨ ខែតុលាឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

សំណាង ស្រីវីន

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

បច្ចុប្បន្ននេះយើងសង្កេតឃើញថាមាន ក្រុមហ៊ុនជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលបានធ្វើការរកស៊ីទៅលើអាជីវកម្មរៀងៗខ្លួន មានទាំងវិស័យឯកជន ឬវិស័យរដ្ឋនោះទេ។ ការរកស៊ីរបស់ក្រុមហ៊ុននីមួយៗតែងតែចង់បានប្រាក់ចំណេញឬចង់បានការអភិវឌ្ឍន៍សេដ្ឋកិច្ចទៅមុខជានិច្ច។ បើយើងក្រឡេកទៅមើលជ្រុងម្ខាងទៀត យើងដឹងហើយថាក្រុមហ៊ុនសព្វថ្ងៃ ដែលកំពុងដំណើរការមានច្រើនប្រភេទដូចជា ក្រុមហ៊ុនសេវាកម្ម ក្រុមហ៊ុនផលិតកម្ម ក្រុមហ៊ុនពាណិជ្ជកម្ម។ល។ ដូច្នេះហើយដើម្បីឱ្យក្រុមហ៊ុនឈរជើងរឹងមាំបានយូរ ទាល់តែក្រុមហ៊ុនធ្វើការជ្រើសរើសអ្នកគ្រប់គ្រងមួយដែលល្អក្នុងការគ្រប់គ្រងទៅលើក្រុមហ៊ុនរបស់ខ្លួន។ ការគ្រប់គ្រងនោះទៀតសោតអ្វីដែរសំខាន់គឺការគ្រប់គ្រងទៅលើ ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

ហេតុនេះហើយ ទើបក្រុមយើងខ្ញុំបានពិភាក្សាគ្នាលើកយកប្រធានបទមួយដែលបានលើកឡើងថា **«ប្រសិទ្ធភាពនៃការគ្រប់គ្រង់សាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង»** ឡើងក្នុងគោលបំណងស្វែងរកគន្លឹះរបៀបនៃការគ្រប់គ្រងសាច់ប្រាក់ដែលធ្វើឱ្យក្រុមហ៊ុនមួយនេះដើរក្នុងភាពជោគជ័យបាន។ ក្រុមហ៊ុនជីបម៉ុង គឺជាក្រុមហ៊ុនបែបពាណិជ្ជកម្ម ប្រភេទទិញលក់ទំនិញ និងផ្តល់សេវាកម្មយ៉ាងល្អជូនដល់អតិថិជនទាំងក្នុង និងក្រៅប្រទេស។ ជាលទ្ធផលក្នុងរុករកអស់ពីសម្តតភាពរបស់ក្រុមនាងខ្ញុំ ពួកយើងបានប្រមូលព័ត៌មានមួយចំនួនដូចជា លក្ខណៈទូទៅនៃការគ្រប់គ្រង សមាសជាតុ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រង រចនាសម្ព័ន្ធ បេសកកម្ម ចក្ខុវិស័យរបស់ក្រុមហ៊ុនជីបម៉ុង និងគន្លឹះសំខាន់ៗដែលបានធ្វើឱ្យក្រុមហ៊ុនមួយនេះឈររឹងមាំមកដល់ពេលបច្ចុប្បន្ន។

ជាចុងក្រោយ ក្រុមនាងខ្ញុំសូមធ្វើការសន្និដ្ឋានថា ក្រុមហ៊ុនជីបម៉ុង គឺជាក្រុមហ៊ុនមួយដែលមានការទទួលស្គាល់ពីប្រទេសនានា។ ហើយក្រុមហ៊ុនជីបម៉ុង ក៏នៅមានបុត្រសម្ព័ន្ធ ដែលហៅថា ជីបម៉ុងគ្រុប ជាច្រើនកន្លែងនូវក្នុងដៃ។ រាល់ការគ្រប់គ្រង់សាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង មួយនេះគឺពិតជាមានយុទ្ធសាស្ត្រក្នុងគ្រប់គ្រង់យ៉ាងមានប្រសិទ្ធភាព និងមានភាពល្អិតល្អន់ ក្នុងក្រុមហ៊ុនទាំងមូលពិតប្រាកដមែន ហើយមិនអាចប្រឈមមុខនឹងបញ្ហាខ្វះខាតហិរញ្ញវត្ថុបានទេ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១. តើក្រុមហ៊ុនជីបម៉ុងមានយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់បែបណាដើម្បីឱ្យមានប្រសិទ្ធភាព ?
២. តើការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពមានផលប៉ះពាល់យ៉ាងដូចម្តេចដល់ក្រុមហ៊ុន ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ១
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី២
## រំលឹកទ្រឹស្តី


២.១ លក្ខណៈទូទៅនៃប្រសិទ្ធនៃការគ្រប់គ្រង ........ ៥
២.១.១ និយមន័យការគ្រប់គ្រង ........ ៥
២.១.២ ប្រវត្តិនៃការគ្រប់គ្រង ........ ៦

២.១.៣ ទ្រឹស្តីនិងតួនាទីនៃការគ្រប់គ្រង ..................................................... ៧
២.២ ប្រសិទ្ធភាពនៃការគ្រប់គ្រង ..................................................... ១០
២.២.១ និយមន័យប្រសិទ្ធភាពនៃការគ្រប់គ្រង ..................................................... ១០
២.២.២ ប្រវត្តិប្រសិទ្ធភាពនៃការគ្រប់គ្រង ..................................................... ១០
២.២.៣ ទ្រឹស្តីនឹងប្រសិទ្ធភាពនៃការគ្រប់គ្រង ..................................................... ១២
២.៣ ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់ ..................................................... ១៤
២.៣.១ និយមន័យផលប៉ះពាល់ការគ្រប់គ្រងសាច់ប្រាក់ ..................................................... ១៤
២.៣.២ ប្រវត្តិនៃផលប៉ះពាល់ក្នុងការគ្រប់គ្រងសាច់ប្រាក់ ..................................................... ១៥
២.៣.៣ ទ្រឹស្តីនៃផលប៉ះពាល់ក្នុងការគ្រប់គ្រងសាច់ប្រាក់ ..................................................... ១៧

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២០
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២០
៣.១.២ ចក្ខុវិស័យ បេសកកម្ម របស់ក្រុមហ៊ុនជីបម៉ុង ..................................................... ២០
ក.ចក្ខុវិស័យ ..................................................... ២០
ខ.បេសកកម្ម ..................................................... ២០
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២១
ក. រចនាសម្ព័ន្ធគ្រប់គ្រង ..................................................... ២១
ខ. តួនាទីគណៈគ្រប់គ្រង ..................................................... ២១
៣.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពរបស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២១
៣.២.១ ប្រសិទ្ធភាពនឹងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២២
៣.២.២ ការវាយតម្លៃនៃការគ្រប់គ្រងសាច់ប្រាក់ ..................................................... ២៣
៣.២.៣ តួនាទី និងភារៈនៃអ្នកគ្រប់គ្រង ..................................................... ២៣
៣.៣ ផលប៉ះពាល់លើប្រសិទ្ធនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២៤
៣.៣.១ ការគ្រប់គ្រងសាច់ប្រាក់កុំឱ្យមានផលប៉ះពាល់ ..................................................... ២៤
ក. ការគ្រប់គ្រងចំណូលនៃការលក់របស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២៥
ខ. ការរៀបចំគម្រោងចំណាយសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង ..................................................... ២៥
៣.៣.២ ការទប់ស្កាត់លើផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង ..... ២៦
៣.៣.៣ គ្រប់គ្រង អតិថិជនឱ្យមានស្ថិរភាព ..................................................... ២៦

៣.៣.៤ ការត្រួតពិនិត្យលើការបាត់បង់ ........................................................................................ ២៦
៣.៣.៥ ការបាត់បង់ហិរញ្ញវត្ថុ ............................................................................................................ ២៧
៣.៣.៦ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង ........................................................................................ ២៧

## ជំពូកទី៤
## វិភាគចំណុចខ្លាំងនឹងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ............................................................................................................ ២៨
៤.២ ការវិភាគលើចំណុចខ្សោយ ......................................................................................................... ២៨

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាននឹងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន ......................................................................................................................... ២៩
៥.២ ការផ្ដល់អនុសាសន៍ ..................................................................................................................... ២៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើង ជាប្រទេសដែលកំពុងអភិវឌ្ឍន៍ហើយរាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងទាក់ទាញអ្នកវិនិយោគឱ្យមកវិនិយោគបានច្រើនលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជាមិនថា វិស័យកសិកម្ម ពាណិជ្ជកម្មឬឧស្សាហ៍កម្ម វាយនភណ្ឌរោងចក្រសហគ្រាស វិស័យទេសចរណ៍និងវិស័យផ្សេងៗជាច្រើនទៀត ដើម្បីជួយពង្រឹងសេដ្ឋកិច្ចជាតិនៅក្នុងប្រទេសកម្ពុជាយើង ឱ្យមានភាពរីកចម្រើនឡើងជាលំដាប់នៅក្នុងនោះផងដែរយើងឃើញមានវិស័យមួយដែរអាចជួយសម្រាលដល់ការធ្វើ អាជីវកម្មទាំងខ្នាតតូចខ្នាតធំឬខ្នាតមធ្យមឱ្យមានដំណើរការបានយ៉ាងល្អលឿន និងឆាប់រហ័សនោះគឺវិស័យពាណិជ្ជកម្ម។

ទន្ទឹមនិងនេះដែរ ការគ្រប់គ្រងលំហូរសាច់ប្រាក់ចេញ និងចូលនៅក្នុងស្ថាប័ននីមួយៗដែរមានប្រតិបត្តិការសាច់ប្រាក់ ជាប្រតិបត្តិការចម្បង ដូចនេះក្រុមហ៊ុនពាណិជ្ជកម្មទាំងអស់តម្រូវឱ្យមានការគ្រប់គ្រង និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឱ្យការគ្រប់គ្រងសាច់ប្រាក់នៅក្នុងក្រុមហ៊ុនរបស់ខ្លួនមានប្រសិទ្ធភាពខ្ពស់។

សរុបមកដោយយល់ឃើញថា ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ គឺជាប្រសិទ្ធភាពមួយដែរមានសារៈសំខាន់នៅក្នុងក្រុមហ៊ុនពាណិជ្ជកម្មដោយបង្ហាញជូនសាធារណៈជន ក្នុងការអាន និងវិភាគ និងធ្វើការសម្រេចចិត្តលើផ្នែកសេដ្ឋកិច្ចរបស់ខ្លួន។ ហេតុដូចនេះហើយ ទើបក្រុមរបស់យើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយដើម្បីលើកយកមកបកស្រាយនោះគឺ **"ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង"**។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយមើលឃើញថា ក្រុមហ៊ុន ជីបម៉ុង គឺជាក្រុមហ៊ុនមួយដែលទទួលបាននូវទំនុកចិត្តពីអតិថិជនជាច្រើនក្នុងការទិញលក់ទំនិញផ្សេងៗ ថែមទាំងបានទាក់ទាញអ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុកឱ្យមកវិនិយោគលើក្រុមហ៊ុនរបស់ខ្លួនបានថែមទៀតផង ដោយសារតែពួកគាត់បានវិភាគទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុននីមួយៗមុននឹងសម្រេចចិត្តធ្វើការវិនិយោគ ប៉ុន្តែក៏នៅមានអតិថិជនមួយចំនួនដែរនៅមានចម្ងល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ដូចជា៖

**១. តើក្រុមហ៊ុនជីបម៉ុងមានយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់បែបណាដើម្បីឱ្យមានប្រសិទ្ធភាព ?**

**២. តើការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពមានផលប៉ះពាល់យ៉ាងដូចម្តេចដល់ក្រុមហ៊ុន ?**

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ ដើម្បីពង្រឹងនូវសមត្ថភាព ចំណេះដឹងថ្មីៗ គំនិតច្នៃប្រឌិត និងឱ្យកាន់តែយល់ច្បាស់នឹងចង់សិក្សាឱ្យកាន់តែស៊ីជម្រៅទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ ប្រកបទៅដោយប្រសិទ្ធភាពខ្ពស់ដែរអាចជឿទុកចិត្តបានយើងត្រូវសិក្សាស្វែងយល់ដូចខាងក្រោម៖

- ស្វែងយល់ពីទ្រឹស្តី និងនិយមន័យនៃប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់
- បង្ហាញពីសមាសធាតុសំខាន់ៗនៅក្នុងការគ្រប់គ្រងសាច់ប្រាក់
- ស្វែងយល់ពីប្រវត្តិ និងស្ថានភាពទូទៅរបស់ក្រុមហ៊ុនជីបម៉ុង

- សិក្សាពីការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង
- សិក្សាអំពីព័ត៌មានដែលបានបង្ហាញនៅក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង
- ពិនិត្យមើលប្រសិទ្ធភាពនឹងលទ្ធផលដែរក្រុមហ៊ុនសម្រេចបាន
- ស្វែងយល់ពីវិធីសាស្ត្រនៅក្នុងប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង។

## ១.៤.ទំហំនិងដែលកំណត់នៃការស្រាវជ្រាវ

### ១.៤.១ ទំហំនឹងដែនកំណត់( Limitation )

ទំហំនឹងដែនកំណត់ នៃការស្រាវជ្រាវនេះក្រុមរបស់យើងខ្ញុំបានលើកយកមកបកស្រាយ នោះគឺប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ និងវិធីសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់ របស់ផ្សារទំនើបជីបម៉ុងនៅសាខាផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាព( Scope )

វិសាលភាពនៃការស្រាវជ្រាវនេះសិក្សាអំពីប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់និងកំណត់ប្រតិបត្តិការទាំងអស់ទាក់ទងនឹងការប្រើប្រាស់ប្រាក់ និងធនធានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ វាជារឿងសំខាន់ក្នុងការអភិវឌ្ឍន៍សកម្មភាពពាណិជ្ជកម្ម និងជួយអភិវឌ្ឍស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។ សម្បូរបែបក្នុងការគ្រប់គ្រងការចំណាយ ការប្រាក់បំណុល ការប្រើប្រាស់ប្រាក់សម្រាប់ការវិនិយោគ និងការជួញដូរសម្រាប់ឆ្នាំ ២០២៣។

## ១.៥.វិធីសាស្ត្រនៃការស្រាវជ្រាវ( Research Methodology )

ការសិក្សាស្រាវជ្រាវលើប្រធានបទ **"ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង"** បានប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដោយផ្តោតជាចម្បងលើ ការវិភាគទិន្នន័យបន្ទាប់បន្សំបានមកពីប្រភពគេហទំព័រ https://www.chipmong.com/en/insider/ ដើម្បីយកមកវិភាគ ក្នុងគោលបំណងបញ្ជាក់ពីការអភិវឌ្ឍ និងការវិវត្តនៃស្តង់ដារបាយការណ៍ហិរញ្ញវត្ថុតាមវិធីសាស្ត្រនឹងសំណួរខាងក្រោម៖

- សម្រាប់សំណួរស្រាវជ្រាវទី១៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យតាមបែបគុណវិស័យ ដោយធ្វើឡើងតាមរយៈទិន្នន័យដែលមានដូចជា សៀវភៅសាណាសិស្សច្បងជំនាន់ទី១៩-២១ នៃសាកលវិទ្យាល័យវ៉ាន់ដា, គេហទំព័រក្រុមហ៊ុន ជីបម៉ុង ( ស្តីពីការគ្រប់គ្រងសាច់ប្រាក់ )។

- សម្រាប់សំណួរស្រាវជ្រាវទី២៖ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ គឺប្រមូលទិន្នន័យបែបគុណវិស័យ ធ្វើឡើងតាមរយៈទិន្នន័យដែលមានដូចជា គេហទំព័រហ្វេសប៊ុកផេកក្រុមហ៊ុន ជីបម៉ុង ជាពិសេសដកស្រង់ពីឯកសារផ្សេងៗ ដែលផ្តោតទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ( The importance of Research )

ការវិភាគរបាយការណ៍នៃការគ្រប់គ្រងសាច់ប្រាក់បានផ្តល់សារៈសំខាន់ចំពោះ ៖

• ក្រុមហ៊ុន

-កំណត់ស្ថានភាពហិរញ្ញវត្ថុ៖ ស្រាវជ្រាវអាចជួយក្រុមសម្រេចបានថាតើមានការគ្រប់គ្រងហិរញ្ញវត្ថុជាល្អ ឬមិនល្អ។ វាជួយទទួលដំណឹងអំពីចំណូល និងចំណាយដើម្បីត្រួតពិនិត្យស្ថានភាពផ្នែកហិរញ្ញវត្ថុ។

- គ្រប់គ្រងគម្រោង និងធនធាន៖ ការស្រាវជ្រាវអាចជួយក្រុមបង្កើតការធ្វើផែនការជាក់លាក់ និងប្រើប្រាស់ធនធានមានស្រាប់ឱ្យមានប្រសិទ្ធភាព។

- ការរៀបចំកម្រងជួរ និងវាយតម្លៃទិន្នន័យ៖ ជំនួយក្នុងការប្រមូលព័ត៌មានត្រឹមត្រូវ និងពិចារណាតាមប្រភពផ្លូវការដើម្បីប្រើប្រាស់សំរាប់គោលបំណងអាជីវកម្ម។

- កំណត់គោលបំណងសហគ្រិន៖ ការស្រាវជ្រាវអាចជួយក្រុមទទួលបានការយល់ដឹងពីតម្រូវការផ្នែកហិរញ្ញវត្ថុដើម្បីអភិវឌ្ឍន៍ផលិតផល ឬសេវាកម្មថ្មីៗ។

- ការបង្កើតគំនិតថ្មី និងមានការសម្រេចចិត្តល្អ៖ ជួយដល់ការសម្រេចចិត្តដោយផ្អែកទៅលើព័ត៌មានជាក់ស្តែងនិងវិស័យស្រាវជ្រាវដែលអាចមានផលប៉ះពាល់ដល់ក្រុមប្រឹក្សាអាជីវកម្ម។

- ក្រុមអ្នកស្រាវជ្រាវ

- ការរីកចម្រើនក្នុងការយល់ដឹងវិជ្ជាជីវៈ៖ អ្នកស្រាវជ្រាវនឹងទទួលបានការយល់ដឹងជាងមុនអំពីវិស័យហិរញ្ញវត្ថុ និងការគ្រប់គ្រងសាច់ប្រាក់។ វាជួយធ្វើឱ្យអ្នកស្រាវជ្រាវមានជំនាញក្នុងការវិភាគ និងវាយតម្លៃគោលនយោបាយហិរញ្ញវត្ថុរបស់ក្រុម ឬអង្គភាពផ្សេងៗ។

- ការអភិវឌ្ឍន៍ជំនាញការស្រាវជ្រាវ៖ ការស្រាវជ្រាវនេះអាចជួយអ្នកស្រាវជ្រាវក្នុងការអភិវឌ្ឍន៍ជំនាញដូចជា៖ ការប្រើប្រាស់ឧបករណ៍ និងទិន្នន័យបច្ចេកទេសក្នុងការវិភាគ និងការបង្ហាញព័ត៌មានសំខាន់ៗដល់អ្នកគ្រប់គ្រង។

- បង្កើតគំនិតថ្មីៗ និងការសម្រេចចិត្ត៖ នៅក្នុងព្រឹត្តិការណ៍នៃការស្រាវជ្រាវដូចនេះ អ្នកស្រាវជ្រាវអាចកែលម្អជំនាញក្នុងការកសាងគំនិតថ្មីៗ និងស្វែងរកដំណោះស្រាយដើម្បីធ្វើឱ្យការគ្រប់គ្រងសាច់ប្រាក់កាន់តែមានប្រសិទ្ធភាព។

- ការពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ៖ ការស្រាវជ្រាវនៃការគ្រប់សាច់ប្រាក់អាចផ្តល់ឱកាសដល់អ្នកស្រាវជ្រាវក្នុងការតភ្ជាប់ជាមួយមនុស្សដែលមានបទពិសោធន៍ និងជំនាញក្នុងវិស័យនេះ។ វាអាចបង្កើតឱកាសសហការជាមួយអ្នកជំនាញផ្សេងទៀត ឬក្រុមហ៊ុនផ្សេងៗ។

- ការព្យាករណ៍និងសម្រេចចិត្តសំខាន់ៗ៖ អ្នកស្រាវជ្រាវអាចប្រើប្រាស់ទិន្នន័យពីការស្រាវជ្រាវនេះដើម្បីព្យាករណ៍លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផ្តល់អនុសាសន៍ដល់ការសម្រេចចិត្តដាក់លាក់ពីផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

- សង្គមជាតិ

- ផ្តល់ដល់អ្នកអានឱ្យយល់ដឹងពីស្ថានភាពហិរញ្ញវត្ថុពិតរបស់ក្រុមហ៊ុន

- ផ្តល់ជាឯកសារ និងយោបល់ខ្លះៗទៅដល់និស្សិតសម្រាប់ស្រាវជ្រាវជំនាន់ក្រោយ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកចេញជា ៥ ជំពូកធំៗដែលមានលក្ខណៈដូចខាងក្រោម ៖

➢ **ជំពូកទី១ (សេចក្តីផ្តើម)**៖ ត្រូវបានបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។

➢ **ជំពូកទី២ (រំលឹកទ្រឹស្តី)**៖ ត្រូវបានលើកឡើងពីទ្រឹស្តីដែលជាប់ពាក់ព័ន្ធ ប្រវត្តិ និងទស្សនទានទាក់ទងនឹងប្រសិទ្ធភាពក្នុងការគ្រប់សាច់ប្រាក់។

- **ជំពូកទី៣ (លទ្ធផលនៃការស្រាវជ្រាវ)៖** ត្រូវលើកយកពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនដូចជា ប្រវត្តិ ចក្ខុវិស័យ បេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រុមហ៊ុន។
- **ជំពូកទី៤ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)៖** វិភាគទៅលើគ្រប់ចំណុចទាំងអស់ ដែលបង្ហាញពីភស្តុតាងយកមកបញ្ជាក់ គឺក្នុងគោលបំណងវិភាគនូវចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើការកែលម្អ។
- **ជំពូកទី៥ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)៖** ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់មតិយោបល់ ឬ អនុសាសន៍ទៅលើចំណុចដែលត្រូវកែតម្រូវ។

# ជំពូកទី២
# ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន

## ២.១ លក្ខណៈទូទៅនៃប្រសិទ្ធភាពនៃការគ្រប់គ្រង

### ២.១.១ និយមន័យនៃការគ្រប់គ្រង

**ការគ្រប់គ្រង** (Management) គឺជាការប្រតិបត្តិការនៅក្នុងស្ថាប័ន ឬអង្គភាព ដើម្បីទទួលបានគោលបំណងនិងអនុវត្តគោលការណ៍នានា ដោយប្រើធនធានមនុស្ស និងធនធានផ្សេងទៀតជាដើម។ វាបង្ហាញពីការតំណាងដឹកនាំ ការរៀបចំការងារ ការត្រួតពិនិត្យ និងការប្រឹងប្រែងដើម្បីធានាថា សកម្មភាពជាច្រើនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព[1]។

គោលគំនិតសកលដែលត្រូវការនៅគ្រប់ស្ថាប័ន មិនថាជាអង្គភាពអាជីវកម្ម ឬអង្គការមិនអាជីវកម្ម ដូចជាសាលា មន្ទីរពេទ្យជាដើមត្រូវបានគេស្គាល់ថាជាការគ្រប់គ្រង។ ភាពជោគជ័យរបស់អង្គការ គឺអាស្រ័យទៅលើដំណើរការជោគជ័យនៃការគ្រប់គ្រងរបស់ខ្លួន ហើយតែងតែត្រូវបានទាមទារនៅពេលណាដែលធនធានមនុស្ស និងមិនមែនមនុស្សរបស់អង្គការធ្វើការរួមគ្នាដើម្បីសម្រេចបាននូវគោលបំណងណាមួយ ក្នុងសម័យបច្ចុប្បន្ន ជាមួយនឹងការកើនឡើងនៃទំហំ និងភាពស្មុគស្មាញនៃអង្គការទំនើបគំនិតនៃការគ្រប់គ្រងបានទទួលនូវសារៈសំខាន់ដ៏ធំធេង[2]។

និយមន័យនៃការគ្រប់គ្រងប្រែប្រួលទៅតាមបរិបទដែលវាត្រូវបានប្រើ។ ក្នុងន័យទូលំទូលាយ ការគ្រប់គ្រងអាចត្រូវបានកំណត់តាមវិធីសាស្ត្រប្រពៃណី និង វិធីសាស្ត្រទំនើប។

-ការគ្រប់គ្រងមានការធ្វើអ្វីៗតាមរយៈអ្នកដទៃ អ្នកគ្រប់គ្រងគឺជាមនុស្សម្នាក់ដែលសម្រេចគោលបំណងដោយដឹកនាំការខិតខំប្រឹងប្រែងរបស់អ្នកដទៃ។ "ការគ្រប់គ្រង គឺជាសិល្បៈនៃការធ្វើអ្វីៗតាមរយៈអ្នកដទៃ"។

-និយមន័យប្រពៃណីនៃការគ្រប់គ្រង គឺមិនច្បាស់លាស់ ដោយសារពួកគេមិនអាចកំណត់មុខងារបានអ្នកគ្រប់គ្រងត្រូវតែអនុវត្តដើម្បីសម្រេចកិច្ចការផ្សេងៗ តាមរយៈអ្នកដទៃ។ លើសពីនេះ និយមន័យទាំងនេះបានផ្តល់នូវចំណាប់អារម្មណ៍លើការអនុវត្តការគ្រប់គ្រងដោយឧបាយកលហើយមិនអើពើនឹងតម្រូវការរបស់កម្មករ ហើយចាត់ទុកពួកគេថាជាមធ្យោបាយដើម្បីទទួលបានលទ្ធផលតាមមធ្យោបាយណាមួយ។

-ការគ្រប់គ្រង គឺជាការបង្កើតបរិយាកាសផ្ទៃក្នុងដែលបុគ្គលធ្វើការជាក្រុមអាចអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធភាពសម្រាប់ការសម្រេចបាននូវគោលដៅរបស់អង្គការ។ ការគ្រប់គ្រងត្រូវបានកំណត់ថាជាដំណើរការនៃការរៀបចំផែនការ ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រងប្រតិបត្តិការរបស់អង្គការមួយ ដើម្បីសម្រេចបាននូវការសម្របសម្រួលនៃធនធានមនុស្ស និងសម្ភារៈចាំបាច់ក្នុងការសម្រេចបាននូវគោលដៅប្រកបដោយប្រសិទ្ធភាព។

### ២.១.២ ប្រវត្តិនៃការគ្រប់គ្រង

ប្រវត្តិនៃការគ្រប់គ្រងបានចាប់ផ្តើមពីសម័យអាណាព្យាបាលបារាំង នៅក្នុងប្រទេសកម្ពុជា។ ក្នុងរបបនេះ ការគ្រប់គ្រងត្រូវបានរៀបចំដោយរដ្ឋាភិបាលថ្នាក់ខេត្ត និងថ្នាក់ឃុំ ដែលមានការបែងចែកតួនាទីនិងការងារដោយច្បាស់លាស់។

[1] Khsearch. ហ៊ូ សម្ផស្ស. (2018, Setember 21). *ដូចម្តេចហៅថាការគ្រប់គ្រង?* Retrieved from https://www.khsearch.com/qna/7930

[2] WordPress. មិត្តនិស្សិត. (2011, May 31). *និយមន័យពាក្យគ្រប់គ្រង* Retrieved from https://clubniset.wordpress.com/2011/05/31/និយមន័យនៃការគ្រប់គ្រង/

បន្ទាប់មក នៅក្នុងរបបសង្គមរាស្ត្រនិយម ការគ្រប់គ្រងត្រូវបានកែប្រែ ដើម្បីផ្តោតលើការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ការគ្រប់គ្រងត្រូវបានរៀបចំឡើងវិញ ដើម្បីធានាថាអង្គភាពរដ្ឋបាលអាចបំពេញតម្រូវការរបស់ប្រជាជនបានយ៉ាងមានប្រសិទ្ធភាព។

ក្នុងសម័យបច្ចុប្បន្ន ការគ្រប់គ្រងត្រូវបានអភិវឌ្ឍន៍ និងកែប្រែ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃសង្គម និងសេដ្ឋកិច្ច។ ការគ្រប់គ្រងទំនើបផ្តោតលើការប្រើប្រាស់ធនធានយ៉ាងមានប្រសិទ្ធភាព និងការបង្កើតតម្លៃសម្រាប់អតិថិជន និងសហគមន៍។

ការគ្រប់គ្រងមានប្រវត្តិធំទូលាយដែលបានកើតឡើងក្នុងការរីកចម្រើននៃសង្គមមនុស្ស។ នៅក្នុងប្រវត្តិរបស់វា អ្នកគ្រប់គ្រងគឺជាអ្នកដែលមានភារកិច្ចក្នុងការគ្រប់គ្រងធនធានមនុស្ស និងធនធានផ្សេងៗ ដើម្បីដំណើរការសកម្មភាពនានានៅក្នុងអង្គការឬក្រុមហ៊ុន។

ប្រវត្តិនៃការគ្រប់គ្រងសំខាន់ៗ

- កាលពីសម័យបុរាណ៖ ប្រវត្តិការគ្រប់គ្រងបានចាប់ផ្តើមនៅក្នុងសង្គមបុរាណ ដូចជា នៅក្នុងអាស៊ី កន្លែងដែលមានការគ្រប់គ្រងព្រមទាំងធនធានធំៗ។ ប្រើប្រាស់ការគ្រប់គ្រងបាននៅក្នុងអាជីវកម្មនានា និងការគ្រប់គ្រងការងារជាលេខាធិការ។

- សម័យពូជនៃការប្រកួតប្រជែង៖ ការគ្រប់គ្រងត្រូវបានបង្កើតឡើងដោយសង្គមពាណិជ្ជកម្ម ដែលការគ្រប់គ្រងត្រូវបានធ្វើបញ្ចូលដោយអាជីវកម្ម និងគ្រប់គ្រងសមាគមពាណិជ្ជកម្មនិងអាជីវកម្មទំនាក់ទំនង។

- សម័យសិល្បៈនៃការគ្រប់គ្រង (Early 20th Century)៖ ក្នុងការអភិវឌ្ឍន៍ដ៏ល្អមួយនេះ ការគ្រប់គ្រងត្រូវបានកែលម្អនិងមានការអភិវឌ្ឍន៍បន្ថែមជាមួយនឹងការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងដែលបានរួមបញ្ចូលគ្នា ដូចជា គ្រប់គ្រងប្រព័ន្ធចំណូលចិត្ត។

- កាលពីសម័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា៖ ការអភិវឌ្ឍន៍បច្ចេកវិទ្យាបានធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។ បច្ចេកវិទ្យានឹងជួយគ្រប់គ្រងការដំណើរការតាមរយៈការត្រួតពិនិត្យ និងវិធីសាស្ត្រជាក់លាក់[3]។

**២.១.៣. ទ្រឹស្តីនៃការគ្រប់គ្រង**

ការគ្រប់គ្រងគឺជាដំណើរការនៃការធ្វើផែនការ រៀបចំ ចាត់ចែង ដឹកនាំ និងត្រួតពិនិត្យធនធានដើម្បីសម្រេចគោលដៅនៃអង្គភាពឬស្ថាប័ន។ ទ្រឹស្តីនៃការគ្រប់គ្រងបានបង្ហាញពីតួនាទីនិងមុខងាររបស់អ្នកគ្រប់គ្រង ដូចខាងក្រោម៖

តួនាទីនៃអ្នកគ្រប់គ្រង

- **តួនាទីអន្តរៈបុគ្គល៖** អ្នកគ្រប់គ្រងត្រូវបំពេញតួនាទីជាអ្នកតំណាង អ្នកដឹកនាំ និងមានតួនាទីទំនាក់ទំនង។
- **តួនាទីព័ត៌មាន៖** អ្នកគ្រប់គ្រងត្រូវប្រមូលព័ត៌មានពីស្ថាប័នខាងក្រៅ តាមដានត្រួតពិនិត្យព័ត៌មាន និងការផ្សព្វផ្សាយ និងមានតួនាទីជាអ្នកនាំពាក្យ។
- **តួនាទីធ្វើការសម្រេចចិត្ត៖** អ្នកគ្រប់គ្រងត្រូវបំពេញតួនាទីជាសហគ្រិន អ្នកដោះស្រាយបញ្ហា បែង

[3] ប៊ុល កុសល ដំណើរការវិវត្តនៃការគ្រប់គ្រងរដ្ឋបាលសាធារៈនៅកម្ពុជាឆ្នាំ១៩៩៣-២០០៣. *ប្រវត្តិនៃការគ្រប់គ្រង"មានន័យដូចម្តេច"* ទំព័រទី១៥-៥៩ Retrieved from https://www.ebooks.libraryrac.com/public/images/files/161163555

ចែកធនធាន និងចរចារ[4]។

មុខងារនៃការគ្រប់គ្រង

- ការធ្វើផែនការ៖ កំណត់គោលដៅ និងវិធីសាស្ត្រដើម្បីសម្រេចគោលដៅនោះ។

- ការរៀបចំចាត់ចែង៖ រៀបចំធនធាន និងកំណត់សកម្មភាពដើម្បីអនុវត្តផែនការដោយមានប្រសិទ្ធភាព។

- ការដឹកនាំ៖ ផ្តល់ការណែនាំ និងលទ្ធភាពដល់បុគ្គល ឬក្រុមដើម្បីអនុវត្តសកម្មភាពតាមផែនការ។

- ការត្រួតពិនិត្យ៖ ត្រួតពិនិត្យការអនុវត្តន៍ និងធ្វើការកែប្រែប្រសើរប្រសិនបើចាំបាច់ ដើម្បីធានាថាសកម្មភាពត្រូវបានអនុវត្តតាមផែនការ[5]។

ការគ្រប់គ្រងត្រូវការតួនាទី និងមុខងារទាំងនេះដើម្បីធានាថាអង្គភាពឬស្ថាប័នអាចសម្រេចគោលដៅបានដោយមានប្រសិទ្ធភាព។

ទ្រឹស្តីសំខាន់ៗនៃការគ្រប់គ្រងមានដូចជា

**១. ទ្រឹស្តីអំពីការគ្រប់គ្រងក្នុងសេដ្ឋកិច្ចសេរី** (Monetary Policy)

ការគ្រប់គ្រងសាច់ប្រាក់ក្នុងសេដ្ឋកិច្ចសេរី ជាផ្នែកមួយទូលំទូលាយហើយវាពិតជាមានសារៈសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចផងដែរ។ សេដ្ឋកិច្ចសេរីមានគោលបំណងនៅក្នុងការគ្រប់គ្រងសាច់ប្រាក់ គឺដើម្បីធានាថាសេដ្ឋកិច្ចអាចដើរទៅមុខ និងធ្វើប្រតិបត្តិការបានយ៉ាងល្អ ដូចដែលរាជរដ្ឋាភិបាលលោកបានសម្រេច និងធនាគារផ្សេងៗនៅក្នុងប្រទេស។

- ការត្រួតពិនិត្យអត្រាភាគរយប្រាក់កម្ចី (Interest Rates)៖ ទ្រឹស្តីនេះប្រាប់ថាអត្រាភាគរយប្រាក់កម្ចីអាចបង្កើតឱ្យមានឥទ្ធិពលលើសេដ្ឋកិច្ចជាលក្ខណៈទូលំទូលាយ ដោយការបន្ថែមឬកាត់បន្ថយអត្រាភាគរយនោះនឹងជួយបង្រួមឬកំណត់សន្ទស្សន៍សេដ្ឋកិច្ចផ្សេងៗ។

- ការត្រួតពិនិត្យបរិមាណប្រាក់ក្នុងប្រព័ន្ធ (Money Supply)៖ ទ្រឹស្តីនេះក៏អនុញ្ញាតឲ្យធនាគារពិចារណានូវកម្រិតនៃការប្រើប្រាស់ប្រាក់ដែលបង់ឬយកចេញពីប្រព័ន្ធហិរញ្ញវត្ថុ តាមការត្រួតពិនិត្យស្តង់ដារនៃបរិមាណប្រាក់។

- ការគ្រប់គ្រងអត្រាកំណត់ (Exchange Rates)៖ ការគ្រប់គ្រងអត្រាប្រាក់បំលែងអាចប្រើប្រាស់នៅក្នុងការត្រួតពិនិត្យសមតុល្យការប្រែប្រួលក្នុងគុណភាពសេដ្ឋកិច្ច និងសំរាប់ការប្តូរប្រាក់ពីប្រទេសមួយទៅប្រទេសផ្សេងៗ។

- **ការគ្រប់គ្រង៖**

- ពង្រឹង និងធានាថាបុគ្គលិកអនុវត្តការងារស្របតាមស្តង់ដាអនុវត្តការងារ (SOP) និងគោលការណ៍របស់ស្ថាប័នឱ្យទទួលបានជោគជ័យ។

- គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវបញ្ជីរបាយការណ៍ទ្រព្យសកម្ម និងសារពើភ័ណ្ឌក្នុងស្ថាប័នឱ្យបានត្រឹមត្រូវ។

[4] KHsearch. ចំណេះដឹងទូទៅ. (2018, September 27 ). *តួនាទីនៃអ្នកគ្រប់គ្រងមានអ្វីខ្លះ?* Retrieved from http://www.khsearch.com/qna/8189

[5] KHsearch. ចំណេះដឹងទូទៅ. (2018, September 27). *មុខនៃការគ្រប់គ្រងមានអ្វីខ្លះ?* Retrieved from http://www.khsearch.com/qna/8186

- រៀបចំ និងចាត់ចែងដាក់ផែនការការងារឱ្យបុគ្គលិកក្រោមបង្គាប់អនុវត្តតាមតួនាទី និងភារកិច្ចនីមួយៗដោយ ធានាថាបុគ្គលិកទាំងអស់អនុវត្តតាមផែនការយុទ្ធសាស្ត្រឱ្យបានជោគជ័យ និងលើកយកលទ្ធផលយកមកប្រជុំរៀងរាល់ខែ ប្រសិទ្ធភាពខ្ពស់ ដើម្បីកែលម្អការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធខ្ពស់។

**•ការគ្រប់គ្រងហិរញ្ញវត្ថុ៖**

គួរជៀសវាងការប្រើគំនិតរបស់អ្នកដទៃ ស្ថាប័នគួរចំណាយពេលវេលាសិក្សា វគ្គបណ្តុះបណ្តាលហិរញ្ញវត្ថុបន្ថែម ក្នុងស្ថាប័នមានភាពរីកចម្រើន។ ព្យាយាមយល់ដឹងអំពីតិចនិចណាដែលធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុមានការវិវត្តន៍ល្អ។

**២. ទ្រឹស្តីអំពីការព្រមព្រៀងវិនិយោគ** (Investment Theories)

ការព្រមព្រៀងវិនិយោគ គឺជាផ្នែកមួយនៃការគ្រប់គ្រងសាច់ប្រាក់ ហើយបានចុះខ្លួនដើម្បីធានានូវការងារដែលមានសុវត្ថិភាពក្នុងការវិនិយោគនូវប្រាក់ក្នុងឱកាសនានា។ នេះមានផ្នែកសំខាន់ៗជាចម្បងដូចជា៖

- ទ្រឹស្តីនៃទឹកប្រាក់ (Liquidity Preference Theory)៖ តាមទ្រឹស្តីនេះ មនុស្សត្រូវការប្រាក់នៅក្នុងស្ថានភាពដែលអាចប្រើប្រាស់បានយ៉ាងឆាប់រហ័ស (liquid assets) ដើម្បីទប់ស្កាត់ករណីនៃការបាត់បង់ភាពសុវត្ថិភាពឬកើតមានការបញ្ចេញប្រាក់ចំណេញនៃវិនិយោគក្នុងរយៈពេលខ្លី។

- ទ្រឹស្តីនៃសំណុំតម្លៃ (Capital Asset Pricing Model - CAPM)៖ តាមទ្រឹស្តីនេះ ប្រើសម្រាប់ការបង្ហាញពីទំនាក់ទំនងរវាងការវិនិយោគ និងការប្រាក់ធនធានដោយពិនិត្យអត្រាចំណូលដែលអាចទទួលបានពីវិនិយោគមួយនៃការគ្រប់គ្រងសាច់ប្រាក់។

**៣. ការគ្រប់គ្រងប្រាក់នៅក្នុងធនាគារ និងសេវាកម្មហិរញ្ញវត្ថុ**

ក្នុងវិស័យធនធានហិរញ្ញវត្ថុ ទ្រឹស្តីនៃការគ្រប់គ្រងសាច់ប្រាក់ផ្តោតលើការអភិវឌ្ឍន៍នៃគ្រប់គ្រងការប្រើប្រាស់សាច់ប្រាក់ដូចជា:

- សមតុល្យកម្ចី និងការប្រាក់ (Loan to Deposit Ratio)៖ ជារបៀបត្រួតពិនិត្យការអនុម័តឥណទាន និងសមតុល្យជាមួយការរក្សាទុកប្រាក់នៅក្នុងធនាគារ។

- ការប្រុងប្រយ័ត្ននៅក្នុងវិធីសាស្ត្រជួញដូរ (Risk Management)៖ ប្រើប្រាស់ការកំណត់វិធានការដែលការពារពីហានិភ័យនៃការបាត់បង់ប្រាក់តាមរយៈការវិនិយោគបែបខុសៗគ្នា។

**៤. ទ្រឹស្តីអំពីសេដ្ឋកិច្ចសន្និសិទ្ធ** (Macroeconomics Theories)

ការគ្រប់គ្រងសាច់ប្រាក់ នៅក្នុងសេដ្ឋកិច្ចត្រូវបានពិចារណានៅក្នុងតម្រូវការផ្ទាល់ពីការរីកចម្រើនសេដ្ឋកិច្ច និងការគ្រប់គ្រងគុណភាពនៃទំនាក់ទំនងសេដ្ឋកិច្ចទាំងមូល ដែលទទួលបាននូវការយកចិត្តទុកដាក់ទៅលើប្រព័ន្ធធនាគារ និងវិស័យផលិតកម្ម។

**• គោលបំណងនៃការគ្រប់គ្រង**

គោលបំណងនៃការគ្រប់គ្រង គឺជាការគ្រប់គ្រងលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញដែលធានាបានថាលំហូរសាច់ប្រាក់ចេញមានកម្រិតទាប និងបង្កើនលំហូរសាច់ប្រាក់ចូលដែល ជួយលើកកម្ពស់ស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រកបដោយប្រសិទ្ធិភាព និងដឹងអំពីបម្រែបម្រួលស្ថានភាព ហិរញ្ញវត្ថុ

គ្រប់សកម្មភាពទាំងលំហូរសាច់ប្រាក់ចេញ និងលំហូរសាច់ប្រាក់ចូលក្នុងមួយកាលបរិច្ឆេទជាក់លាក់ណាមួយរបស់ស្ថាប័ន។ ដើម្បីគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពមានចំណុចសំខាន់ដូចខាងក្រោម៖

**ក. រក្សាការកត់ត្រាឱ្យបានទៀងទាត់**

ការតាមដានប្រាក់ចំណូល និងចំណាយដែលពាក់ព័ន្ធដោយផ្ទាល់នឹងសាច់ប្រាក់ គឺជាមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រង។ ទោះបីជាប្រព័ន្ធដែលផ្ទុកក្នុងកុំព្យូទ័រជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការតាមដាន និងរក្សាតុល្យភាពរវាងទ្រព្យសកម្មចរន្ត និងបំណុលអកម្មក៏ដោយ ក៏ត្រូវមានការកត់ត្រាផ្ទាល់ដៃផងដែរ ក្នុងការអនុវត្តនូវកិច្ចការនេះ។

**ខ. ការគ្រប់គ្រងផ្ទៃក្នុង**

ការគ្រប់គ្រងសាច់ប្រាក់ គឺជាកត្តាសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវភាពជាក់លាក់ ឬទៀងទាត់។ ដើម្បីការពារ និងធ្វើឱ្យច្បាស់ថាការប្រតិបត្តិការរបស់ស្ថាប័នមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ ក្នុងនោះរាប់បញ្ចូលទាំងការសរសេរគោលនយោបាយប្រើប្រាស់សាច់ប្រាក់ឱ្យបានច្បាស់លាស់ ក៏ដូចជានីតិវិធី ប្រតិបត្តិការមានលក្ខណៈស្តង់ដា ដែលបង្កើតឡើងនូវតវិយាបថរំពឹងទុក និងបង្កើតភាពអាចទទួលខុសត្រូវបាន។

**គ. ការព្យាករណ៍ទុក និងការរៀបចំផែនការ**

ការរៀបចំផែនការពីគម្រោងលំហូរសាច់ប្រាក់ក្នុងរយៈពេលវែងប្រចាំឆ្នាំ និងអំឡុងពេលខ្លីប្រចាំខែ វាអាចជួយឱ្យអ្នកយល់ដឹងពីការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃដែលចាំបាច់ ក៏ដូចជាអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រដែល អាចសម្រេចទិសដៅរយៈពេលវែង។ ការបញ្ចេញគំនិតល្អៗថា ពេលណា ទីណា និងសាច់ប្រាក់ចំនួនប៉ុន្មាន ដែលជានិច្ចកាលប្រតិបត្តិការរបស់ស្ថាប័នត្រូវការច្រើនបំផុតដើម្បីរៀបចំឱ្យប្រសើរជាងមុន ហើយអាចកាត់បន្ថយ ឬលុបបំបាត់ការខ្ចីជាប្រភពមូលនិធិរយៈពេលខ្លី។ បន្ថែមពីនេះ ការវិភាគអំពីកំហុសឆ្គងដែលមានកន្លងមកអាចជួយឱ្យយើងចៀសផុតពីកំហុសច្រំដែល និងឈានដល់ការគ្រប់គ្រងសាច់ប្រាក់កាន់តែប្រសើរឡើង។

**ឃ. សាច់ប្រាក់ដែលត្រូវទទួលបាន**

នីតិវិធីក្នុងការប្រមូលសាច់ប្រាក់ គឺមានសារៈសំខាន់ណាស់ក្នុងការទទួលបាននូវសាច់ប្រាក់។ កត្តានេះ ក៏រាប់បញ្ចូលផងដែរ នូវការធ្វើឱ្យបានច្បាស់លាស់នៃវិក័យប័ត្រប្រចាំខែទៀងទាត់ និងទាន់ពេលវេលា, ការពិនិត្យ បច្ច័យប្រាក់ចំណូលដែលទទួលបាន និងពិសោធន៍ឱ្យឃើញដូចគ្នានូវបណ្តាសកម្មភាពដែលបានបង់ប្រាក់យឺតយ៉ាវ, ការបង្កើតនីតិវិធីផ្សេងៗសម្រាប់អនុវត្តលើការបង់ប្រាក់យឺតយ៉ាវ, និងការពង្រឹងនូវគោលការណ៍ណែនាំ ក្នុងការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធដែលបានបង់ ឬទូទាត់លើវិក័យប័ត្រមុនពេលកំណត់[6]។

**សេចក្តីសង្ខេប**

ទ្រឹស្តីនៃការគ្រប់គ្រង គឺមានលក្ខណៈសំខាន់សម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ច និងភាពស្ថិរភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ។ វាបង្ហាញពីការអភិវឌ្ឍន៍នៃគោលការណ៍ធនធានហិរញ្ញវត្ថុ ការប្រើប្រាស់ប្រាក់ និងការត្រួតពិនិត្យវិនិយោគក្នុងរយៈពេលវែង ដែលធានាពីសុវត្ថិភាព និងភាពមានប្រសិទ្ធភាពក្នុងប្រព័ន្ធសេដ្ឋកិច្ច។

[6] ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (May, 2024). *ទ្រឹស្តីគោលបំណងនៃការគ្រប់គ្រង.* ទំព័រ៣៦. Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf

## ២.២. ប្រសិទ្ធភាពនៃការគ្រប់គ្រង

### ២.២.១. និយមន័យប្រសិទ្ធភាពនៃការគ្រប់គ្រង

ប្រសិទ្ធភាពនៃការគ្រប់គ្រង (Management Effectiveness) គឺជាការវាស់វែងថាតើសកម្មភាពនិងយុទ្ធសាស្ត្រគ្រប់គ្រងដែលបានអនុវត្តសម្រេចបានលទ្ធផលដែលអាចសម្រេចនូវគោលបំណង និងគោលនយោបាយរបស់អង្គភាព ឬក្រុមហ៊ុនឬអង្គការណាមួយ ឬក៏មិនបានសម្រេចដល់គោលបំណងនោះទេ។ ប្រសិទ្ធភាពនេះមិនត្រឹមតែសំដៅលើការប្រតិបត្តិការនិងផលិតផលផ្នែកបុគ្គលិកទេ ប៉ុន្តែសម្រាប់ការសម្រេចនូវទិសដៅនឹងគោលបំណងទូទៅរបស់អង្គភាពផងដែរនូវក្នុងការគ្រប់គ្រងចំណូលចំណាយ។

### ២.២.២. ប្រវត្តិប្រសិទ្ធភាពនៃការគ្រប់គ្រង

ការគ្រប់គ្រងមានប្រវត្តិធំធេងនិងពិបាក ដោយវាត្រូវបានអភិវឌ្ឍន៍មកពីការរីកចម្រើននៃអង្គការនានា និងទំនាក់ទំនងបណ្តាញសង្គមដែលទាក់ទងនឹងការគ្រប់គ្រងជាការប្រព្រឹត្តសកម្មភាពនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ប្រវត្តិនៃគ្រប់គ្រងបានបន្ថែមតំបន់កាន់តែធំៗ ដោយមកពីរយៈពេលពីការអភិវឌ្ឍន៍គំនិតមូលដ្ឋាន ( Classical management theories) ទៅប្រព័ន្ធទំនាក់ទំនងមនុស្ស ( Human relations) និងការគ្រប់គ្រងទំនាក់ទំនងសង្គម ( Contingency approach) នៅក្នុងសកលវិស័យជាមួយនឹងអភិវឌ្ឍន៍នៃគំនិតបច្ចេកទេសថ្មីៗទាក់ទងនឹងការអនុវត្តគ្រប់គ្រងដូចជាការប្រើប្រាស់បច្ចេកវិទ្យា និងការប្រើប្រាស់ម៉ូដែលបច្ចេកវិទ្យា។

#### ១. ការគ្រប់គ្រងទូទៅ

ការគ្រប់គ្រងទូទៅ (General Management) គឺជាការគ្រប់គ្រងដែលមានទំនួលខុសត្រូវទៅលើការត្រួតពិនិត្យ និងដំណើរការផ្សេងៗក្នុងអង្គភាព ឬ អាជីវកម្ម។ វាសម្រាប់ដឹកនាំ គ្រប់គ្រងធនធាន និងកំណត់គោលបំណងដើម្បីសម្រេចបាននូវលទ្ធផលល្អប្រសើរ។

ការគ្រប់គ្រងទូទៅភាគច្រើនអាចបែងចែកជាចំណុចសំខាន់ៗដូចជា៖

ក. ការគ្រប់គ្រងធនធានមនុស្ស៖ ផ្តោតលើការជ្រើសរើស បណ្តុះបណ្តាល និងការកំណត់យុទ្ធសាស្ត្រអ្នកធ្វើការដែលសមស្របសម្រាប់អង្គភាព។

ខ. ការគ្រប់គ្រងហិរញ្ញវត្ថុ៖ គ្រប់គ្រងលទ្ធផលហិរញ្ញវត្ថុ ដូចជា ការប្រើប្រាស់ប្រាក់ចំណូល ការយកចិត្តទុកដាក់ទៅលើការចំណាយ និងផលចំណេញ។

គ. ការគ្រប់គ្រងប្រតិបត្តិការ៖ ការបង្កើត និងដំណើរការជាចលនា ដែលជួយបញ្ចប់គោលបំណង និងបញ្ចប់ការងារប្រកបដោយប្រសិទ្ធភាព។

#### ២. ការគ្រប់គ្រងអង្គភាព

ការគ្រប់គ្រងអង្គភាព (Organization Management) គឺជាការគ្រប់គ្រង និងសម្រួលការងារផ្សេងៗក្នុងអង្គភាព ឬអង្គការផ្សេងៗ ដើម្បីធានាថាការងារនានាត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។ វារួមមានការកំណត់គោលបំណងយុទ្ធសាស្ត្រ ការបែងចែកធនធាន និងការត្រួតពិនិត្យប្រតិបត្តិការដោយមានការប្រាស្រ័យទាក់ទងយ៉ាងស៊ីជម្រៅក្នុងអង្គភាព។

ដើម្បីធានាបាននូវការគ្រប់គ្រងអង្គភាពដែលមានប្រសិទ្ធភាព ការគ្រប់គ្រងត្រូវការពិចារណាទៅលើអនុគមន៍ជាច្រើនដូចជា៖

ក. ការគ្រប់គ្រងធនធានមនុស្ស៖ យ៉ាងដូចជាការជ្រើសរើស បណ្តុះបណ្តាល និងការបង្ហាញពីការអភិវឌ្ឍន៍សមត្ថភាព។

ខ. ការរៀបចំសហគ្រិនភាព៖ ការពង្រឹងការទំនាក់ទំនង និងការបែងចែកអំណាចក្នុងអង្គភាព។

គ. ការត្រួតពិនិត្យ និងវាយតម្លៃ៖ ការតាមដាន និងវាយតម្លៃប្រសិទ្ធភាពក្នុងការអនុវត្តគោលបំណង និងយុទ្ធសាស្ត្រទាំងមូល។

### ៣. ប្រភេទនៃការគ្រប់គ្រង

ការគ្រប់គ្រង (Management) គឺជាអនុស្សាវរណ៍សំខាន់ៗក្នុងការប្រតិបត្តិការអាជីវកម្មនិងអង្គភាព។ ប្រភេទនៃការគ្រប់គ្រងអាចត្រូវបានចែកចេញជាច្រើន ប្រើប្រាស់សម្រាប់គោលបំណងនិងទិសដៅផ្សេងៗ។ ខាងក្រោមគឺជាប្រភេទនៃការគ្រប់គ្រងចម្បងៗ៖

ក. ការគ្រប់គ្រងប្រតិបត្តិការនៃអង្គភាព (Operations Management)៖ ប្រភេទនេះទាក់ទងនឹងការគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃក្នុងអង្គភាព។ វាអាចរួមបញ្ចូលការគ្រប់គ្រងនូវផលិតកម្ម, ប្រព័ន្ធនៃដំណើរការ និងការប្រតិបត្តិការ។

ខ. ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)៖ គ្រប់គ្រងហិរញ្ញវត្ថុទាក់ទងនឹងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់អង្គភាព។ វារួមបញ្ចូលការរៀបចំថវិកា, ការគ្រប់គ្រងប្រាក់ចំណូល ចំណាយ និងវិភាគហិរញ្ញវត្ថុ។

គ. ការគ្រប់គ្រងមនុស្សធម៌ (Human Resource Management)៖ ប្រភេទនេះនិយាយអំពីការរក្សាទុក និងគ្រប់គ្រងធនធានមនុស្សក្នុងអង្គភាព។ វារៀបចំការជ្រើសរើសបុគ្គលិក, ការអភិវឌ្ឍន៍សមត្ថភាព និងការអភិវឌ្ឍន៍កិច្ចការនៃការលើកកម្ពស់បុគ្គល។

ឃ. ការគ្រប់គ្រងទីផ្សារ (Marketing Management)៖ គឺជាការគ្រប់គ្រងទៅលើការផ្សព្វផ្សាយផលិតផលឬសេវាកម្មទៅកាន់ទីផ្សារ។ វារួមបញ្ចូលក្នុងការស្រាវជ្រាវទីផ្សារ, ការគ្រប់គ្រងគំនិតផលិតផល, និងករណីផ្សព្វផ្សាយ។

ង. ការគ្រប់គ្រងគម្រោង (Project Management)៖ ប្រភេទនេះទាក់ទងនឹងការគ្រប់គ្រងគម្រោងឱ្យបញ្ចប់ដោជ័យ។ វាមានការពិចារណាអំពីការគ្រប់គ្រងពេលវេលា, ថវិកា និងធនធានដទៃទៀត។

ច. ការគ្រប់គ្រងវិស័យព័ត៌មាន (Information Technology Management)៖ ការគ្រប់គ្រងនេះទាក់ទងនឹងការគ្រប់គ្រងឧបករណ៍ និងប្រព័ន្ធព័ត៌មានក្នុងអង្គភាព, រួមមានការអភិវឌ្ឍន៍ និងការគ្រប់គ្រងទិន្នន័យ និងការពារ។

### ៤. យុទ្ធសាស្ត្រនៃការគ្រប់គ្រង

យុទ្ធសាស្ត្រនៃការគ្រប់គ្រង គឺជាគោលការណ៍ និងវិធីសាស្ត្រដែលអ្នកគ្រប់គ្រងប្រើប្រាស់ដើម្បីឆ្លើយតបនឹងបញ្ហាក្នុងអង្គភាព និងធ្វើឱ្យអង្គភាពនោះដំណើរការយ៉ាងមានប្រសិទ្ធភាព និងប្រសើរ។ យុទ្ធសាស្ត្រនេះមានការប្រើប្រាស់ការគ្រប់គ្រងទាំងអស់ដូចជា គ្រប់គ្រងធនធានមនុស្ស, គ្រប់គ្រងហិរញ្ញវត្ថុ,និង គ្រប់គ្រងការផលិត។

ប្រភេទនៃយុទ្ធសាស្ត្រនៃការគ្រប់គ្រង មានការរួមបញ្ចូលយុត្តិធម៌ផ្សេងៗដូចជា៖

ក. ការគ្រប់គ្រងកម្រិតខ្ពស់ (Strategic Management)៖ ការអនុវត្តន៍យុទ្ធសាស្ត្រដែលមានអារម្មណ៍ជាខ្ពស់ ដែលមានគោលបំណងដើម្បីជំរុញកំណត់បំណងសំខាន់ៗនៃអង្គភាព។

ខ. ការគ្រប់គ្រងជាក់ស្តែង (Tactical Management)៖ វាអះអាងពីការអនុវត្តន៍យុទ្ធសាស្ត្រនៅក្នុងកម្រិតផ្នែកណាមួយ។

គ. ការគ្រប់គ្រងប្រចាំថ្ងៃ (Operational Management)៖ ជាប្រភេទការគ្រប់គ្រងនៅកម្រិតប្រចាំថ្ងៃដើម្បីធ្វើឱ្យអង្គភាពប្រើប្រាស់ធនធានក្នុងការប្រតិបត្តិការពិតប្រាកដ។

ចំណុចគន្លងក្នុងការគ្រប់គ្រង មានដូចជា៖

- ការរចនាយុទ្ធសាស្ត្រប្រកួតប្រជែង
- ការបែងចែកធនធានតាមប្រសិទ្ធភាព
- ការបង្កើនសមត្ថភាពសកម្មភាព
- ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល

**៥. បញ្ហានៃការគ្រប់គ្រង**

ការគ្រប់គ្រងមានបញ្ហាផ្សេងៗ ដែលអាចបង្ហាញអំពីការលំបាកក្នុងការប្រតិបត្តិការនិងការដឹកនាំសហគ្រាស។ នៅក្នុងការអនុវត្តន៍ការគ្រប់គ្រង វាអាចជួបប្រទះនឹងបញ្ហាផ្សេងៗដូចជា៖

ក. ការគ្រប់គ្រងធនធានមនុស្ស៖ ជាមុខងារសំខាន់ក្នុងការអភិវឌ្ឍន៍ និងគ្រប់គ្រងក្រុមបុគ្គលិកសម្រាប់ការអនុវត្តន៍អាជីវកម្មត្រូវការការបណ្តុះបណ្តាល និងការបង្កើតការពិចារណាដែលល្អ។

ខ. ការព្រួយបារម្ភពីការផ្លាស់ប្តូរទីផ្សារ៖ ការគ្រប់គ្រងត្រូវតែបំពេញតាមតម្រូវការផ្លាស់ប្តូរទីផ្សារនិងបង្កើតគោលបំណងឱ្យទាន់ពេលវេលា។

គ. ការចំណាយនិងការសន្សំ៖ បញ្ហាដែលសំខាន់នៃការគ្រប់គ្រងគឺការគ្រប់គ្រងកំណត់ថវិកានិងការសន្សំទ្រព្យសកម្ម។

ឃ. ការអភិវឌ្ឍន៍នវានុវត្តន៍៖ ត្រូវការជំនាញក្នុងការតាមដាននិងអនុវត្តន៍នវានុវត្តន៍ដើម្បីឱ្យសហគ្រាសអាចដំណើរការបានប្រសើរឡើង។

**២.២.៣. ទ្រឹស្តីនៃការគ្រប់គ្រង**

ទ្រឹស្តីនៃការគ្រប់គ្រង( Management Theories ) គឺជាចំណេះដឹងនិងគោលការណ៍ដែលអ្នកគ្រប់គ្រងប្រើប្រាស់ដើម្បីបង្កើតអភិវឌ្ឍន៍ការងារផ្សេងៗនៃអង្គការផ្សេងៗ។ ទ្រឹស្តីនេះគាំទ្រការគ្រប់គ្រងធនធាន ប្រព័ន្ធ និងការងារផ្សេងៗក្នុងអង្គការដើម្បីឱ្យមានប្រសិទ្ធភាព និងផលប្រយោជន៍អតិបរមា។

**១. ទ្រឹស្តីសំខាន់ៗនៃការគ្រប់គ្រង** (Monetary Policy)

ទ្រឹស្តីការគ្រប់គ្រងភាគច្រើនត្រូវបានកំណត់ក្នុងការគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចដោយសារធនាគារកណ្តាលឬរាជរដ្ឋាភិបាល។ វាកំណត់ពីការចេញផ្សាយប្រាក់ និងការត្រួតពិនិត្យអត្រាការប្រាក់។ គោលបំណងសំខាន់ៗរបស់គោលនយោបាយនេះមានដូចជា៖

- ការត្រួតពិនិត្យបរិមាណប្រាក់: គ្រប់គ្រងការផលិតប្រាក់និងការលៃតម្រូវប្រាក់ដែលមាននៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។

- ការកំណត់អត្រាភាគរយប្រាក់កម្ចី: ធនាគារកណ្តាលអាចកំណត់អត្រាភាគរយក្នុងការខ្ចីប្រាក់ដែលនឹងមានឥទ្ធិពលលើការចំណាយនិងការវិនិយោគរបស់អតិថិជន និងសហគ្រាស។

- ការត្រួតពិនិត្យសេដ្ឋកិច្ច: ការកំណត់គោលនយោបាយសំរាប់ការត្រួតពិនិត្យសេដ្ឋកិច្ចដើម្បីកំណត់ភាពសមរម្យរបស់ប្រាក់។

**ប្រភេទគោលនយោបាយសេដ្ឋកិច្ច:**

- គោលនយោបាយជំរុញ (Expansionary Monetary Policy): វាបង្កើតស្ថានភាពដែលបញ្ចេញប្រាក់ច្រើនជាងដែលមានក្នុងប្រព័ន្ធ ដើម្បីបង្កើនការចំណាយ និងការវិនិយោគ។

- គោលនយោបាយកាត់បន្ថយ (Contractionary Monetary Policy): វាផ្តោតលើការកាត់បន្ថយបរិមាណប្រាក់ក្នុងប្រព័ន្ធដើម្បីត្រួតពិនិត្យអតិផរណា និងការចំណាយ។

**២. ទ្រឹស្តីអំពីការគ្រប់គ្រងចំណាយនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច** (Keynesian Theory)

- គោលការណ៍សំខាន់: ព្រមទាំងការគ្រប់គ្រងសាច់ប្រាក់, ទ្រឹស្តីជួញដូរ (Keynesian economics) មើលឃើញថាការគ្រប់គ្រងសាច់ប្រាក់ត្រូវបានប្រើសម្រាប់ការផ្តល់អត្ថប្រយោជន៍ឱ្យសេដ្ឋកិច្ចមានការចំណាយលើផលិតកម្ម និងវិនិយោគ ពីព្រោះមនុស្សប្រើប្រាស់ប្រាក់ច្រើន, ការចំណាយនឹងធ្វើឱ្យមានការពង្រីកសេដ្ឋកិច្ច។

- ការបញ្ជាក់: ការផ្តល់ប្រាក់គ្រប់គ្រងអត្រាការប្រាក់ និងការចំណាយនឹងជួយបង្កើតកិច្ចការសំរាប់ការអភិវឌ្ឍន៍មួយក្នុងសេដ្ឋកិច្ច។

**៣. ទ្រឹស្តីអំពីការគ្រប់គ្រងប្រព័ន្ធធនាគារកណ្តាល** (Central Bank Theory)

ការគ្រប់គ្រងប្រាក់គឺជាការកំណត់ការផលិតប្រាក់ដែលអាចប្រើបាននៅក្នុងប្រព័ន្ធធនធានហិរញ្ញវត្ថុ។ ទ្រឹស្តីនេះបង្ហាញថាធនាគារកណ្តាលគួរត្រូវតែមានអំណាចក្នុងការត្រួតពិនិត្យសេដ្ឋកិច្ចដោយផ្តល់សេវាកម្មដល់ធនាគារពាណិជ្ជកម្ម និងធនាគាររដ្ឋាភិបាលនៅក្នុងប្រព័ន្ធសេដ្ឋកិច្ច។

- មូលដ្ឋាននៃធនធាន៖ ប្រាក់កំណត់ជាលក្ខណៈប្រព័ន្ធរបស់ធនាគារកណ្តាល ដើម្បីត្រួតពិនិត្យមើលសេដ្ឋកិច្ច។

**៤. ទ្រឹស្តីការព្រមព្រៀងវិនិយោគ** (Investment Theories)

ទ្រឹស្តីវិនិយោគគ្រប់គ្រងប្រាក់នឹងមិនត្រឹមតែគ្រប់គ្រងបរិមាណប្រាក់ក្នុងសេដ្ឋកិច្ចទេ តែមានការរៀបចំចំណូលរបស់វា សម្រាប់ការវិនិយោគក្នុងវិស័យផ្សេងៗ ដើម្បីអាចដោះស្រាយបញ្ហាផ្ទុយទៅពីការកំណត់វិធីសាស្ត្រជីវិត។

- ទ្រឹស្តីលទ្ធផលធ្វើជាសកម្មភាព: បង្កើតតម្លៃអំពីការគ្រប់គ្រងក្នុងវិស័យនិងវិបត្តិការណ៍ដែលជាការអភិវឌ្ឍន៍នៃសេដ្ឋកិច្ច។

**៥. ទ្រឹស្តីការពារ និងភាពរលូនសេដ្ឋកិច្ច** (Stability and Liquidity Theory)

- ការត្រួតពិនិត្យសេដ្ឋកិច្ច: ទ្រឹស្តីនៃការត្រួតពិនិត្យសេដ្ឋកិច្ចនឹងកំណត់ថាអាចធានានូវស្ថិរភាពដោយសកម្មភាពពហុធនាគារ និងអត្រាសំរាប់បញ្ចូលការចំណាយ។

**សេចក្តីសង្ខេប**

ទ្រឹស្តីការគ្រប់គ្រងបង្ហាញពីការអនុវត្តន៍នៃការត្រួតពិនិត្យការប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការការពារអតិផរណា។ វាបង្កើតការផលិតនៃទ្រឹស្តីក្នុងការធានាសុវត្ថិភាពវិនិយោគ និងការរីកចម្រើនល្អក្នុងការគ្រប់គ្រងសេដ្ឋកិច្ច។

**ចំណុចសំខាន់សម្រាប់ការរៀបចំផែនការសាច់ប្រាក់រួមមាន៖**

- ភាពប្រស៊ីគ្នាជាមួយនឹងការព្យាករណ៍ថវិកាប្រចាំឆ្នាំជាសាច់ប្រាក់ ដែលត្រូវការសម្រាប់អនុវត្តថវិកាប្រចាំឆ្នាំ និងធ្វើបច្ចុប្បន្នភាពនៃលំហូរសាច់ប្រាក់ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ និងប្រចាំខែ ដោយព្យាករណ៍ថវិកាប្រចាំឆ្នាំ (ផ្អែកលើសាច់ប្រាក់)

- ផ្តោតលើលំហូរចូល និងលំហូរចេញសំខាន់ៗ ដើម្បីធានាថាការព្យាករណ៍សម្រាប់ចំណូលសំខាន់ៗ និងចំណាយសំខាន់ៗឱ្យមានភាពច្បាស់លាស់ដែលអាចធ្វើទៅបាន

- ការកំណត់អំពីទិន្នន័យនិងព័ត៌មាននៃលំហូរចូល និងលំហូរចេញសាច់ប្រាក់ជាក់លាក់ដែលបានអនុវត្តកាលពីឆ្នាំមុន

- ការកំណត់ពេលវេលានៃលំហូរសាច់ប្រាក់សំខាន់ៗ (លំហូរធំមួយចំនួនគឺជាក់លាក់ទៅតាមពេលវេលា និងអាចត្រូវបានកំណត់ជាមុន ទាំងនេះរួមមាន៖ ការទូទាត់បំណុល, ការទូទាត់ប្រាក់បៀវត្ស ការទូទាត់លើគម្រោងរបស់ស្ថាប័នសំខាន់ៗ, និងប្រាក់សោធននិវត្តន៍ ឬសុខុមាលភាពជាដើម)

- ការបញ្ជាក់ពីតម្រូវការសាច់ប្រាក់លើការចំណាយ ស្ថាប័នត្រូវរៀបចំគម្រោងចំណាយរបស់ខ្លួនឱ្យត្រូវ នឹងចំណូលដែលទទួលបាន។ វាមានសារៈសំខាន់ណាស់ក្នុងការធានាថាស្ថាប័នបានរៀបចំផែនការហិរញ្ញវត្ថុទាំងកាលវិភាគនៃលំហូរចូល និងលំហូរចេញសាច់ប្រាក់

- ការចែករំលែកព័ត៌មានពីការគ្រប់គ្រងការចំណាយ ស្ថាប័នត្រូវធានាថាព័ត៌មានដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងគឺ សម្រាប់តែការគ្រប់គ្រងសាច់ប្រាក់ប៉ុណ្ណោះ មិនមែនព័ត៌មានគ្រប់គ្រងចំណាយទេ

- ការព្យាករណ៍ផែនការសាច់ប្រាក់ ចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំខែ និងប្រចាំឆ្នាំ[7]។

## ២.៣. ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់

### ២.៣.១. និយមន័យផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់

ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់ (Cash Management Impacts) គឺជាការប៉ះពាល់នានាដែលកើតឡើងអាស្រ័យលើរបៀបស្ថាប័ន ឬអង្គភាពមួយគ្រប់គ្រងនិងប្រើប្រាស់សាច់ប្រាក់របស់ខ្លួន៖

១. ផលប៉ះពាល់វិជ្ជាជីវៈ

- បង្កើនសមត្ថភាពក្នុងការទូទាត់បំណុល និងការជៀសវាងពីបញ្ហាឥណទាន។
- ជួយក្នុងការរៀបចំផែនការហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធិភាព។
- បន្ថយការបាត់បង់ពីស្ថានភាពសាច់ប្រាក់ខ្វះឬលើស។

២. ផលប៉ះពាល់សេដ្ឋកិច្ច

- ជួយបង្កើនស្ថិរភាពសេដ្ឋកិច្ចក្នុងវិស័យឯកជន។

[7] ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (May, 2024). *តើការរៀបចំផែនការសាច់ប្រាក់.* ទំព័រ៣៦. *Retrieved from* https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf

• ការគ្រប់គ្រងសាច់ប្រាក់ល្អអាចនាំឲ្យមានការវិនិយោគបន្ថែម។
• ជួយបន្ថយហានិភ័យនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុជាសកល។

៣. ផលប៉ះពាល់បច្ចេកវិទ្យា

• បង្កើតជម្រើសសម្រាប់ E-banking, Mobile Payment, និងការចែកចាយសេវាហិរញ្ញវត្ថុតាមបណ្ដាញ។
• ផ្ដល់លក្ខណៈអចិន្ត្រៃយ៍ និងភាពងាយស្រួលដល់អាជីវកម្ម[8]។

**២.៣.២ ប្រវត្តិនៃផលប៉ះពាល់ក្នុងការគ្រប់គ្រងសាច់ប្រាក់**

ប្រវត្តិនៃផលប៉ះពាល់ក្នុងការគ្រប់គ្រងសាច់ប្រាក់មានការផ្លាស់ប្ដូរ អស់រយៈពេលយូរពីសតវត្សរ៍មួយទៅសតវត្សរ៍មួយទៀត។ នៅក្នុងប្រវត្តិសាស្ត្រ គ្រប់គ្រងសាច់ប្រាក់ត្រូវបានគ្រប់គ្រងតាមវិធីសាស្ត្រផ្សេងៗគ្នាដែលមានសារៈសំខាន់ៗសូមបញ្ជាក់ពីការផ្លាស់ប្ដូរមុខងារ និងវិធីសាស្ត្រពីមួយដំណាក់កាលទៅមួយដំណាក់កាលមានដូចខាងក្រោម[9]។

**ក. ការប្រើប្រាស់ប្រាក់ក្នុងបុរាណ** (Commodities and Metal Currency)

នៅក្នុងពេលបុរាណ, មនុស្សបានប្រើប្រាស់វត្ថុធម្មជាតិដែលមានតម្លៃជាប្រាក់ដើម្បីធ្វើជាជំនួសសម្រាប់ការជួញដូរ។ ការប្រើប្រាស់ប្រាក់គ្រាប់ (Commodity money) ដូចជា ប្រាក់ដែក, មាស, និងសមុទ្រជារបៀបដើមតំណាលសម្រាប់អនុវត្តន៍សេដ្ឋកិច្ច។ ប្រទេសចិន គឺបានផ្ដាច់មុខក្នុងការបង្កើតប្រាក់ក្រដាស (paper money) នៅប្រហែលក្នុងសតវត្សទី ១១ (ប្រាក់ក្រដាសបានបង្ហាញជាលើកដំបូងនៅក្នុងសម្រាប់ការជួញដូរ និងការសងប្រាក់)។

**ខ. ប្រាក់កាត និងការកំណត់ទ្រឹស្តីសេដ្ឋកិច្ច**

នៅក្នុងសតវត្សទី ៦-១១ ក្រោមការគ្រប់គ្រងអ៊ីរ៉ង់ និងបាប៊ីឡូន (Babylon) ក្នុងប្រទេសគឺបានបង្កើតប្រាក់កាត (Coinage) ដែលត្រូវបានគ្រប់គ្រងដោយរាជាធិបតេយ្យ ដើម្បីបង្កើតសុវត្ថិភាព និងបញ្ជាក់ពីតម្លៃរបស់ប្រាក់តាមវិធីមួយច្បាស់លាស់។ នៅក្នុងសតវត្សទី ១៨-១៩ ប្រទេសអឺរ៉ុបបានចាប់ផ្ដើមកំណត់របបគ្រប់គ្រងសាច់ប្រាក់ និងការផលិតប្រាក់តាមតម្លៃមាស ដែលធ្វើឡើងតាមរបៀបសេដ្ឋកិច្ចកំណត់កម្រិតប្រាក់ដែលអាចបញ្ចេញមកបាន។

**គ. ទ្រឹស្តីប្រាក់មូលនិធិ និងការគ្រប់គ្រងសេដ្ឋកិច្ច**

នៅក្នុងសតវត្សទី ១៨ និង ១៩ ប្រព័ន្ធសេដ្ឋកិច្ចមូលនិធិក៏ត្រូវបានបង្កើតដោយរដ្ឋបាលធនធានហិរញ្ញវត្ថុដែលប្រើប្រាស់ការបញ្ចូលប្រាក់កំណត់តម្លៃ ដើម្បីគ្រប់គ្រងដល់ការត្រួតពិនិត្យទំនាក់ទំនងក្នុងកម្រិតប្រាក់។ ដូច្នេះ ព្រះរាជាធិបតេយ្យបានបង្កើតមូលនិធិដែលបញ្ជាលើវិធីសាស្ត្រសម្រាប់ការអនុវត្តន៍ប្រាក់តាមការគ្រប់គ្រងដែលមានសមាជិកដូចជា សេដ្ឋកិច្ចចំណេញនិងការពារប្រាក់ពីវិបត្តិ។

[8] Investopedia. (2024, September 23). *ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់.* Retrieved from https://www.investopedia.com/terms/c/cash-management.asp
[9] ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (2024, May). *ប្រវត្តិនៃការគ្រប់គ្រងសាច់ប្រាក់.* ទំព័រទី៨. Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf

**ឃ. ការបង្កើតសេដ្ឋកិច្ចសេរី និងកំណត់ជំពូកសេដ្ឋកិច្ចសកល**

ក្រោយពីពេលជំរុញសេដ្ឋកិច្ចសេរីនៅក្នុងសតវត្សទី២០ ការគ្រប់គ្រងសាច់ប្រាក់កាន់តែចូលរួមក្នុងការត្រួតពិនិត្យប្រព័ន្ធធនធានហិរញ្ញវត្ថុ។ ធនាគារកណ្តាលក្រុមហ៊ុន ក៏បានកំណត់ប្រព័ន្ធទូទាត់មួយដែលធានាបាននូវសុវត្ថិភាពសម្រាប់ការផលិតប្រាក់។ ការត្រួតពិនិត្យប្រើប្រាស់ប្រាក់គឺធ្វើការត្រួតពិនិត្យការផលិតប្រាក់ធម្មជាតិ ក្នុងកម្រិតកំណត់សម្រាប់ការបញ្ចេញប្រាក់ ដែលមានតម្លៃឧបត្ថម្ភសម្រាប់ការតភ្ជាប់ក្នុងប្រព័ន្ធសេដ្ឋកិច្ចលើសេវាកម្មធនធាន។

**ង. បញ្ហាសេដ្ឋកិច្ចសេរី និងវិបត្តិនៃសាច់ប្រាក់**

បញ្ហាសេដ្ឋកិច្ចសេរី និងវិបត្តិនៃសាច់ប្រាក់ គឺជាថ្នាក់មួយនៃប្រធានបទសំខាន់ក្នុងវិស័យសេដ្ឋកិច្ច។ វាបង្ហាញពីការរីកចម្រើន និងវិបត្តិនានា ដែលអាចមានអត្តសញ្ញាណដោយមុខងារអចិន្ត្រៃជាតិ និងប្រជាជនធ្វើការជាមួយបញ្ហា សេដ្ឋកិច្ចសេរី។ យ៉ាងច្រើនវាបញ្ជាក់ថា ការរីកចម្រើនសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចសេរីមានភាពច្រើន និងតម្រូវការច្រើន។

**. ការប្រើប្រាស់ប្រាក់គ្រាប់** (Commodity Money)

នៅក្នុងសតវត្សរ៍ដំបូង, មនុស្សប្រើប្រាក់ដែលធ្វើពីវត្ថុធម្មជាតិដូចជា តាមប្រាក់ដែក, សមុទ្រឬ មាស, ដែលមានតម្លៃដោយសារវិធីសាស្រ្តនិងគុណភាពរបស់វា។ វាជាប្រព័ន្ធប្រើប្រាស់ដែលមានមូលដ្ឋានតាមកញ្ចប់វត្ថុ។

**. ប្រាក់កាត** (Coinage)

ការប្រើប្រាស់ប្រាក់កាតដូចជាមាស និងប្រាក់កែវបានកំណត់ក្នុងប្រទេសផ្សេងៗចាប់ពីសតវត្សទី ៦ BCE នៅលើភាគហ៊ុនសាសន៍យ៉ុងណាន ប្រើប្រាស់ប្រាក់កាតដើម្បីជួយគ្រប់គ្រង និងអនុវត្តន៍ការផលិតការជួញដូរ ។

**. ការបង្ហាញការប្រើប្រាស់ប្រាក់សំរាប់ការតបតទាន និងប្រព័ន្ធវិស័យទុន** (Paper Money)

នៅសតវត្សទី១១ និងទី១២ ប្រទេសចិនបានបង្កើតប្រាក់ក្រដាសដំបូងសម្រាប់ការជួញដូរ។ ប្រាក់ក្រដាសនេះធ្វើឱ្យការជួញដូរ កាន់តែមានប្រសិទ្ធភាព និងកាន់តែល្អប្រសើរ។ ប្រព័ន្ធនេះត្រូវបាននាំចូលទៅប្រទេសអឺរ៉ុបនៅលើយុគ្រិស្តកម្ម។

**. ធនធានមូលនិធិ និងធនាគារ**

នៅក្នុងសតវត្សទី១៧ និងទី១៨ ប្រទេសទាំងអស់បានបង្កើតនៅប្រព័ន្ធធនាគារដោយចំនួនបន្ទាប់ពីការផលិតប្រាក់ក្រដាសកាន់តែមានប្រសិទ្ធភាព។ ធនាគារបានធ្វើការរក្សាទុក និងគ្រប់គ្រងសាច់ប្រាក់ជាពាណិជ្ជកម្ម, ការផលិតប្រាក់, និងការបញ្ជូនប្រាក់ទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុរបស់ប្រទេស។

**. ប្រព័ន្ធប្រាក់ជាតិ និងសេដ្ឋកិច្ចសេរី**

នៅក្នុងសតវត្សទី២០, ប្រព័ន្ធសាច់ប្រាក់បានផ្លាស់ប្តូរទៅប្រើប្រាស់ក៏ដោយសេដ្ឋកិច្ចសេរី។ ប្រព័ន្ធសេដ្ឋកិច្ចលើកដំណើរឡើងកាន់កំពូល ជាមួយការប្រើប្រាស់ប្រាក់ជាតិធម្មតា និងការបង្កើតកម្រិតការកំណត់នៅលើប្រាក់របស់រាជរដ្ឋាភិបាលដើម្បីគ្រប់គ្រងគោលការណ៍សេដ្ឋកិច្ច។

. ការគ្រប់គ្រងសាច់ប្រាក់នៅបច្ចុប្បន្ន

ការគ្រប់គ្រងសាច់ប្រាក់បច្ចុប្បន្នគឺទាក់ទងនឹងការប្រើប្រាស់ប្រាក់ឌីជីថល និងបច្ចេកវិទ្យាដូចជាប្រាក់ប៊ីតគោល (Cryptocurrency) និងកម្មវិធីទូទាត់អេឡិចត្រូនិច។ សហគមន៍ហិរញ្ញវត្ថុបានកំណត់គោលការណ៍និងវិនិយោគប្រព័ន្ធប្រើប្រាស់សំរាប់ការពារ និងការរក្សាទុកសាច់ប្រាក់ក្នុងរបៀបដ៏មានប្រសិទ្ធភាព និងសុវត្ថិភាព។ ប្រព័ន្ធនៃការគ្រប់គ្រងសាច់ប្រាក់បានបត់បែននិងបែបផ្សេងៗទៅតាមការផ្លាស់ប្តូរនៃប្រព័ន្ធសេដ្ឋកិច្ច និងបច្ចេកវិទ្យា[10]។

**២.៣.៣. ទ្រឹស្តីនៃផលប៉ះពាល់ក្នុងការគ្រប់គ្រងសាច់ប្រាក់**

ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់ ( Cash Management Impacts ) គឺជាការប៉ះពាល់នានាដែលកើតឡើងអាស្រ័យលើរបៀបនៃស្ថាប័ន ឬអង្គភាពមួយគ្រប់គ្រងនិងប្រើប្រាស់សាច់ប្រាក់របស់ខ្លួន។

**១.ទ្រឹស្តីអំពីការគ្រប់គ្រងសាច់ប្រាក់ក្នុងសេដ្ឋកិច្ចសេរី** (Monetary Policy)

ការគ្រប់គ្រងសាច់ប្រាក់ក្នុងសេដ្ឋកិច្ចសេរី ជាផ្នែកមួយទូលំទូលាយហើយវាពិតជាមានសារៈសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចផងដែរ។ សេដ្ឋកិច្ចសេរីមានគោលបំណងនៅក្នុងការគ្រប់គ្រងសាច់ប្រាក់ គឺដើម្បីធានាថាសេដ្ឋកិច្ចអាចដើរទៅមុខ និងធ្វើប្រតិបត្តិការបានយ៉ាងល្អ ដូចដែលរាជរដ្ឋាភិបាលលោកបានសម្រេច និងធនាគារផ្សេងៗនៅក្នុងប្រទេស។

- ការត្រួតពិនិត្យអត្រាភាគរយប្រាក់កម្ចី (Interest Rates): ទ្រឹស្តីនេះប្រាប់ថាអត្រាភាគរយប្រាក់កម្ចីអាចបង្កើតឱ្យមានឥទ្ធិពលលើសេដ្ឋកិច្ចជាលក្ខណៈទូលំទូលាយ ដោយការបន្ថែមឬកាត់បន្ថយអត្រាភាគរយនោះនឹងជួយបង្រួមឬកំណត់សន្ទស្សន៍សេដ្ឋកិច្ចផ្សេងៗ។
- ការត្រួតពិនិត្យបរិមាណប្រាក់ក្នុងប្រព័ន្ធ (Money Supply): ទ្រឹស្តីនេះក៏អនុញ្ញាតឲ្យធនាគារពិចារណានូវកម្រិតនៃការប្រើប្រាស់ប្រាក់ដែលបង់ឬយកចេញពីប្រព័ន្ធហិរញ្ញវត្ថុ តាមការត្រួតពិនិត្យស្តង់ដារនៃបរិមាណប្រាក់។
- ការគ្រប់គ្រងអត្រាកំណត់ (Exchange Rates): ការគ្រប់គ្រងអត្រាប្រាក់បំលែងអាចប្រើប្រាស់នៅក្នុងការត្រួតពិនិត្យសមតុល្យការប្រែប្រួលក្នុងគុណភាពសេដ្ឋកិច្ច និងសំរាប់ការប្តូរប្រាក់ពីប្រទេសមួយទៅប្រទេសផ្សេងៗ។

**ការគ្រប់គ្រង៖**

- ពង្រឹង និងធានាថាបុគ្គលិកអនុវត្តការងារស្របតាមស្តង់ដាអនុវត្តការងារ (SOP) និងគោល ការណ៍របស់ស្ថាប័នឱ្យទទួលបានជោគជ័យ
- គ្រប់គ្រង និងត្រួតពិនិត្យជាប្រចាំនូវបញ្ជីរបាយការណ៍ទ្រព្យសកម្ម និងសារពើភ័ណ្ឌក្នុងស្ថាប័ន ឱ្យបានត្រឹមត្រូវ
- រៀបចំ និងចាត់ចែងដាក់ផែនការការងារឱ្យបុគ្គលិកក្រោមបង្គាប់អនុវត្តតាមតួនាទីនិងភារកិច្ចនីមួយៗដោយ ធានាថាបុគ្គលិកទាំងអស់អនុវត្តតាមផែនការយុទ្ធសាស្ត្រឱ្យបានជោគជ័យ និង លើកយកលទ្ធ

[10] ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (May, 2024). *បញ្ហាសេដ្ឋកិច្ចសេរីនិងវិបត្តិនៃសាច់ប្រាក់.* ទំព័រទី៤៤. Retrieved form https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf

ផលយកមកប្រជុំរៀងរាល់ខែ ប្រសិទ្ធភាពខ្ពស់ ដើម្បីកែលម្អការអនុវត្តន៍ការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់[11]។

**ការគ្រប់គ្រងហិរញ្ញវត្ថុ៖**

គួរជៀសវាងការប្រើគំនិតរបស់អ្នកដទៃ ស្ថាប័នគួរចំណាយពេលវេលាសិក្សា វគ្គបណ្ដុះបណ្ដាលហិរញ្ញវត្ថុបន្ថែម ក្នុងស្ថាប័នមានភាពរីកចម្រើន។ ព្យាយាមយល់ដឹងអំពីតិចនិចណាដែលធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុ។

**២. ទ្រឹស្តីអំពីការព្រមព្រៀងវិនិយោគ** (Investment Theories)

ការព្រមព្រៀងវិនិយោគ គឺជាផ្នែកមួយនៃការគ្រប់គ្រងសាច់ប្រាក់ ហើយបានចុះខ្លួនដើម្បីជានានូវការងារដែលមានសុវត្ថិភាពក្នុងការវិនិយោគនូវប្រាក់ក្នុងឱកាសនានា។ នេះមានផ្នែកសំខាន់ៗជាចម្បងដូចជា៖

- ទ្រឹស្តីនៃទឹកប្រាក់ (Liquidity Preference Theory): តាមទ្រឹស្តីនេះ មនុស្សត្រូវការប្រាក់នៅក្នុងស្ថានភាពដែលអាចប្រើប្រាស់បានយ៉ាងឆាប់រហ័ស (Liquid assets) ដើម្បីទប់ស្កាត់ករណីនៃការបាត់បង់ភាពសុវត្ថិភាពឬកើតមានការបញ្ចេញប្រាក់ចំណេញនៃវិនិយោគក្នុងរយៈពេលខ្លី។

- ទ្រឹស្តីនៃសំណុំតម្លៃ (Capital Asset Pricing Model - CAPM): ទ្រឹស្តីនេះប្រើសម្រាប់ការបង្ហាញពីទំនាក់ទំនងរវាងការវិនិយោគនិងការប្រាក់ធនធានដោយពិនិត្យអត្រាចំណូលដែលអាចទទួលបានពីវិនិយោគមួយនៃការគ្រប់គ្រងសាច់ប្រាក់។

**៣. ការគ្រប់គ្រងប្រាក់នៅក្នុងធនាគារ និងសេវាកម្មហិរញ្ញវត្ថុ**

ក្នុងវិស័យធនធានហិរញ្ញវត្ថុ ទ្រឹស្តីនៃការគ្រប់គ្រងសាច់ប្រាក់ផ្តោតលើការអភិវឌ្ឍន៍នៃគ្រប់គ្រងការប្រើប្រាស់សាច់ប្រាក់ដូចជា៖

- សមតុល្យកម្ចី និងការប្រាក់ (Loan to Deposit Ratio): ជារបៀបត្រួតពិនិត្យការអនុម័តឥណទាន និងសមតុល្យជាមួយការរក្សាទុកប្រាក់នៅក្នុងធនាគារ។

- ការប្រុងប្រយ័ត្ននៅក្នុងវិធីសាស្រ្តជួញដូរ (Risk Management): ប្រើប្រាស់ការកំណត់វិធានការដែលការពារពីហានិភ័យនៃការបាត់បង់ប្រាក់តាមរយៈការវិនិយោគបែបខុសៗគ្នា។

**៤. ទ្រឹស្តីអំពីសេដ្ឋកិច្ចសន្និសិទ្ធ** (Macroeconomics Theories)

ការគ្រប់គ្រងសាច់ប្រាក់នៅក្នុងសេដ្ឋកិច្ចត្រូវបានពិចារណានៅក្នុងតម្រូវការផ្ទាល់ពីការរីកចម្រើនសេដ្ឋកិច្ច និងការគ្រប់គ្រងគុណភាពនៃទំនាក់ទំនងសេដ្ឋកិច្ចទាំងមូល ដែលទទួលបាននូវការយកចិត្តទុកដាក់ទៅលើប្រព័ន្ធធនាគារ និងវិស័យផលិតកម្ម។

**•គោលបំណងនៃការគ្រប់គ្រងសាច់ប្រាក់**

គោលបំណងនៃការគ្រប់គ្រងសាច់ប្រាក់គឺជាការគ្រប់គ្រងលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញ ដែលធានាបានថាលំហូរសាច់ប្រាក់ចេញមានកម្រិតទាប និងបង្កើនលំហូរសាច់ប្រាក់ចូលដែលជួយលើកកម្ពស់ស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព និងដឹងអំពីបម្រែបម្រួលស្ថានភាព

[11] ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (2024, May). *តើការរៀបចំផែនការសាច់ប្រាក់ ?* ទំព័រទី៤៤. Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf

ហិរញ្ញវត្ថុគ្រប់សកម្មភាពទាំងលំហូរសាច់ប្រាក់ចេញ និងលំហូរសាច់ប្រាក់ចូលក្នុងការិយបរិច្ឆេទដាក់លាក់ណាមួយរបស់ស្ថាប័ន។ ដើម្បីគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពមានចំណុចសំខាន់ដូចខាងក្រោម៖

**ក. រក្សាការកត់ត្រាឱ្យបានទៀងទាត់**

ការតាមដានប្រាក់ចំណូល និងចំណាយដែលពាក់ព័ន្ធដោយផ្ទាល់នឹងសាច់ប្រាក់ គឺជាមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រង។ ទោះបីជាប្រព័ន្ធដែលផ្ទុកក្នុងកុំព្យូទ័រជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការតាមដាន និងរក្សាតុល្យភាពរវាងទ្រព្យសកម្មចរន្ត និងបំណុលអកម្មក៏ដោយ ក៏ត្រូវមានការកត់ត្រាផ្ទាល់ដៃផងដែរក្នុង ការអនុវត្តនូវកិច្ចការនេះ។

**ខ. ការគ្រប់គ្រងផ្ទៃក្នុង**

ការគ្រប់គ្រងសាច់ប្រាក់ គឺជាកត្តាសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវភាពដាក់លាក់ ឬទៀងទាត់។ ដើម្បីការពារ និងធ្វើឱ្យច្បាស់ថាការប្រតិបត្តិការរបស់ស្ថាប័នមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយក្នុងនោះរាប់បញ្ចូលទាំងការសរសេរគោលនយោបាយប្រើប្រាស់សាច់ប្រាក់ឱ្យបានច្បាស់លាស់ ក៏ដូចជានីតិវិធី ប្រតិបត្តិការមានលក្ខណៈស្តង់ដា ដែលបង្កើតឡើងនូវតរិយាបថរំពឹងទុក និងបង្កើតភាពអាចទទួលខុសត្រូវបាន។

**គ. ការព្យាករទុក និងការរៀបចំផែនការ**

ការរៀបចំផែនការពីគម្រោងលំហូរសាច់ប្រាក់ក្នុងរយៈពេលវែងប្រចាំឆ្នាំ និងអំឡុងពេលខ្លីប្រចាំខែ វាអាចជួយឱ្យអ្នកយល់ដឹងពីការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃដែលចាំបាច់ ក៏ដូចជាអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រដែល អាចសម្រេចទិសដៅរយៈពេលវែង។ ការបញ្ចេញគំនិតល្អៗថា ពេលណា ទីណា និងសាច់ប្រាក់ចំនួនប៉ុន្មាន ដែលជានិច្ចកាលប្រតិបត្តិការរបស់ស្ថាប័នត្រូវការច្រើនបំផុតដើម្បីរៀបចំឱ្យប្រសើរជាងមុន ហើយអាចកាត់ បន្ថយ ឬលុបបំបាត់ការខ្ចីជាប្រភពមូលនិធិរយៈពេលខ្លី។ បន្ថែមពីនេះ ការវិភាគអំពីកំហុសឆ្គងដែលមានកន្លង មកអាចជួយឱ្យយើងចៀសផុតពីកំហុសច្រំដែល និងឈានដល់ការគ្រប់គ្រងសាច់ប្រាក់កាន់តែប្រសើរឡើង។

**ឃ. សាច់ប្រាក់ដែលត្រូវទទួលបាន**

នីតិវិធីក្នុងការប្រមូលសាច់ប្រាក់ គឺមានសារៈសំខាន់ណាស់ក្នុងការទទួលបាននូវសាច់ប្រាក់។ កត្តានេះ ក៏រាប់បញ្ចូលផងដែរ នូវការធ្វើឱ្យបានច្បាស់លាស់នៃវិក័យប័ត្រប្រចាំខែទៀងទាត់ និងទាន់ពេលវេលា, ការពិនិត្យ បច្ច័យប្រាក់ចំណូលដែលទទួលបាន និងពិសោធន៍ឱ្យឃើញដូចគ្នានូវបណ្តាលសកម្មភាពដែលបានបង់ប្រាក់យឺត យ៉ាវ, ការបង្កើតនីតិវិធីផ្សេងៗសម្រាប់អនុវត្តលើការបង់ប្រាក់យឺតយ៉ាវ, និងការពង្រឹងនូវគោលការណ៍ណែនាំ ក្នុងការលើកទឹកចិត្តដល់អ្នកពាក់ព័ន្ធដែលបានបង់ ឬទូទាត់លើវិក័យប័ត្រមុនពេលកំណត់។

**សេចក្តីសង្ខេប**

ទ្រឹស្តីនៃការគ្រប់គ្រងសាច់ប្រាក់ គឺមានលក្ខណៈសំខាន់សម្រាប់ការរីកចម្រើននៃសេដ្ឋកិច្ច និងភាពស្ថិរភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុ។ វាបង្ហាញពីការអភិវឌ្ឍន៍នៃគោលការណ៍ធនធានហិរញ្ញវត្ថុ ការប្រើប្រាស់ប្រាក់ និងការត្រួតពិនិត្យវិនិយោគក្នុងរយៈពេលវែង ដែលធានាពីសុវត្ថិភាព និងប្រសិទ្ធភាពក្នុងប្រព័ន្ធសេដ្ឋកិច្ច។

# ជំពូកទី៣
# ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន ជីបម៉ុង

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ជីបម៉ុង

ដំបូងចាប់ផ្តើម ពីជំនួញត្រឹមលក់ដែកអេតចាយចាស់ៗនៅឆ្នាំ១៩៨២ បច្ចុប្បន្ននេះជីបម៉ុងគ្រុប មានដៃជើងដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធសឹងតែគ្រប់វិស័យតែម្តង មិនថាដែក សំណង់ ម្ហូបអាហារ លំនៅដ្ឋាន ហើយថ្មីៗនេះទៀតសោតគឺ ធនាគារ។ នៅពីក្រោយភាពជោគជ័យមកដល់សព្វថ្ងៃរបស់ក្រុមហ៊ុន ជីបម៉ុង អាចនិយាយថាគឺជាសំណាងផង និងការតស៊ូប្រឹងប្រែង ប្រកបដោយភាពឆ្លាតវៃផង ព្រោះជំនួញដំបូងគឺជាការនាំដែកធ្វើសំណង់ចូល ហើយចំពេលដែលពេលនោះវាមានត្រូវការស្រាប់ ខ្លួនក៏អាចឈរជើងរឹងមាំមកដល់ឥឡូវ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម របស់ក្រុមហ៊ុនជីបម៉ុង

#### ក. ចក្ខុវិស័យ

ចក្ខុវិស័យរបស់ក្រុមហ៊ុន ជីប ម៉ុង នឹងក្លាយជាក្រុមហ៊ុនខ្នាតធំ ដែល ទទួលបានការគោរព និងការសរសើរបំផុតក្នុងតំបន់។ គោលតម្លៃរបស់យើងគឺ សហការដោយតាំងចិត្ត បង្កើតថ្មីពិត ដើម្បីចម្រើន បរិច្ចាគទៅសង្គមឱ្យបានច្រើន គំនិតថ្កើងថ្កាន ផ្តោតលើអតិថិជន។ ដោយមានចក្ខុវិស័យ និងគោលតម្លៃ ជាមួយនឹងកិច្ចប្រឹងប្រែងដោយគ្មាន ការនឿយហត់របស់និយោជិត ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការអនុវត្តសម្រាប់ការងារប្រកបដោយវិជ្ជាជីវៈល្អឥតខ្ចោះ យើងនឹងបន្តភាពជោគជ័យដ៏ អស្ចារ្យរបស់យើងក្នុងការផលិតប្រកបដោយគុណភាពខ្ពស់បំផុត និងផ្តល់សេវា ល្អបំផុតដល់អតិថិជន។ ក្រុមហ៊ុន ជីបម៉ុង គឺជាជម្រើសដ៏ល្អរបស់អតិថិជនជាច្រើន ពីព្រោះតែអតិថិជនជឿជាក់លើយើង ដោយយើងផ្តោតលើគុណភាព ជាចម្បង និងការចែកចាយទាន់ពេលវេលា។ ជោគជ័យដ៏អស្ចារ្យនេះ គឺបានមកពីការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ហើយនិយោជិត ម្ចាស់ភាគហ៊ុន និងអ្នកជាប់ពាក់ព័ន្ធទាំងអស់មានការប្តេជ្ញាចិត្តខ្ពស់។ ដូច្នេះឆ្លៀតឱកាសនេះ ខ្ញុំសូមសម្តែងការដឹងគុណដ៏ស្មោះដល់អ្នកគ្រប់ គ្នាដែលបានរួមចំណែកផ្តល់ជាវិភាគទានដល់ភាពជោគជ័យនេះ។ ក្រុមហ៊ុន ជីបម៉ុង បានរក្សាកិត្តិយសក្នុងនាមជាអ្នកនាំមុខក្នុងពាណិជ្ជកម្មលើ ច្រើនវិស័យដូចជា ការអភិវឌ្ឍលំនៅឋាន បេតុងលាយស្រេច ការចែកចាយ និងផលិតស៊ីម៉ងត៍ ការចែកចាយផលិតផលបរិភោគ ការផលិតស្រាបៀរ និង ភេសជ្ជៈ។ល។ តាមរយៈសមត្ថភាព ការប្រកួតប្រជែង និងការចែកចាយទាន់ ពេលវេលា ជាមួយបទដ្ឋានគុណភាពខ្ពស់បំផុត។

#### ខ. បេសកកម្ម

ក្រុមហ៊ុន ជីបម៉ុង ប្តេជ្ញាចិត្តក្នុងការផលិត និងផ្តល់ផលិតផល និងសេវាកម្មលំដាប់ពិភពលោកជាជម្រើសរបស់អតិថិជន រីកចម្រើនតាមរយៈរួមបញ្ចូលគ្នា និងការទិញ ឬពហុជំនួញនាំមុខទាំងការបង្កើត និងការអនុវត្តយុទ្ធសាស្ត្រនីរន្តរភាព។ ក្រុមហ៊ុន ជីបម៉ុង គឺជាក្រុមហ៊ុនដ៏មានឥទ្ធិពលមួយនៅកម្ពុជា ដែលមានសកម្មភាពយ៉ាងសកម្មក្នុងវិស័យជាច្រើន។ ក្រុមហ៊ុនបានចាប់ផ្តើមពីការផលិត និងចែកចាយស៊ីម៉ងត៍ បន្ទាប់មកពង្រីកទៅវិស័យផ្សេងៗដូចជា ការអភិវឌ្ឍលំនៅដ្ឋាន ការផលិតស្រាបៀរ និងសេវាធនាគារ។ នៅក្នុងវិសយធនាគារ ក្រុមហ៊ុន ជីបម៉ុង បានបង្កើតធនាគារ ជីបម៉ុង ដែលមានសាខាច្រើនទូទាំងប្រទេស និងផ្តល់

សេវាឌីជីថលដើម្បីបំពេញតម្រូវការរបស់អតិថិជន។ ក្រុមហ៊ុន ជីបម៉ុង ក៏មានការចូលរួមយ៉ាងសកម្មក្នុងការផ្តល់ជំនួយសង្គម ដោយបានចូលរួមជាមួយប្រមុខរាជរដ្ឋាភិបាល និងផ្តល់ជំនួយក្នុងវិស័យជាច្រើននៅ កម្ពុជា។ សរុបមក ក្រុមហ៊ុន ជីបម៉ុង បានបង្ហាញពីការរីកចម្រើន និងការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជាដោយផ្តល់ផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់ក្រុមហ៊ុន ជីបម៉ុង

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង




#### ខ. តួនាទីគណៈគ្រប់គ្រង

ក្រុមហ៊ុន ជីបម៉ុង គឺជាក្រុមហ៊ុនពហុវិស័យដែលមានរចនាសម្ព័ន្ធគ្រប់គ្រងតាមរយៈក្រុមហ៊ុនបុត្រសម្ព័ន្ធជាច្រើន។ តួនាទីគណៈកម្មការគ្រប់គ្រងរបស់ក្រុមហ៊ុនមានដូចជា៖

- ក្រុមប្រឹក្សាភិបាល៖ ដឹកនាំ និងគ្រប់គ្រងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុន
- អ្នកគ្រប់គ្រងជាន់ខ្ពស់៖ អនុវត្តយុទ្ធសាស្ត្រនិងគ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃ
- ក្រុមហ៊ុនបុត្រសម្ព័ន្ធ៖ មានតួនាទីក្នុងវិស័យផ្សេងៗ ដូចជា សំណង់ ផលិតផលបរិភោគ និងធនាគារ។

## ៣.២ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង

យុទ្ធសាស្ត្រសំខាន់ៗក្នុងការគ្រប់គ្រងសាច់ប្រាក់ឱ្យទទួលបានប្រសិទ្ធភាពរបស់ក្រុមហ៊ុនមានដូចជា៖

1. ការកំណត់នូវប្រភពចំណូលចំណាយហិរញ្ញវត្ថុ ឱ្យបានច្បាស់លាស់
2. ការរៀបចំផែនការសាច់ប្រាក់ឱ្យបានច្បាស់លាស់ ការកំណត់កំរិតសាច់ប្រាក់ប្រចាំថ្ងៃ
3. ត្រួតពិនិត្យរាល់ចំណូលចំណាយ ធៀបជាមួយផែនការ
4. រៀបចំ និងត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃ

5. រៀបចំ និងវិភាគលំហូរសាច់ប្រាក់ចេញចូល
6. ចាត់ចែង និងវិនិយោគសាច់ប្រាក់ដែលលើសពីតម្រូវការប្រើប្រាស់ឱ្យបានត្រឹមត្រូវ។

**៣.២.១ ប្រសិទ្ធភាពនិងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីប ម៉ុង**

ប្រសិទ្ធភាព និងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង ( JP Morqgan Chase ) គឺជាប្រធានបទដែលមានការសំខាន់មួយក្នុងវិស័យហិរញ្ញវត្ថុ និងគ្រប់គ្រងហិរញ្ញវត្ថុ។ ជីបម៉ុង ជាក្រុមហ៊ុនធំមួយនៅលើពិភពលោក ដែលផ្តល់សេវាផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ ហើយមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសាច់ប្រាក់សម្រាប់អតិថិជន និងផ្នែកទិញលក់។

ការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន នេះចូលរួមដំណើរការជាមួយបច្ចេកវិទ្យាថ្មីៗ ដូចជាបច្ចេកវិទ្យាថ្មីក្នុងការពិចារណាពីជំនួញ និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗ។ ក្រុមហ៊ុនបានអនុវត្តឧបករណ៍ គ្រប់គ្រងសាច់ប្រាក់ដូចជា (Liquidity Management) ដើម្បីធានាថាក្រុមហ៊ុនមានសាច់ប្រាក់ គ្រប់គ្រាន់សម្រាប់ដំណើរការប្រចាំថ្ងៃ និងការចំណាយធនធានប្រកបដោយប្រសិទ្ធភាព។

ដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់ គឺជាយុទ្ធសាស្ត្រ និងឧបករណ៍ដែលត្រូវបានរចនាឡើងដើម្បីបង្កើនប្រសិទ្ធភាពការគ្រប់គ្រងសាច់ប្រាក់ និងសាច់ប្រាក់ក្នុងស្ថាប័នមួយ។ ពួកគេដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងលំហូរសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាព។

- **អត្ថប្រយោជន៍នៃដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់៖**

ការអនុវត្តដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់ប្រកបដោយប្រសិទ្ធភាពអាចនាំឱ្យលំហូរសាច់ប្រាក់ប្រសើរឡើង កាត់បន្ថយការចំណាយ និងការធ្វើផែនការហិរញ្ញវត្ថុកាន់តែប្រសើរឡើង។

- **ប្រភេទនៃដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់៖**

មានដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់ផ្សេងៗ រួមទាំងប្រព័ន្ធគ្រប់គ្រងធនាគាឧបករណ៍ព្យាករណ៍សាច់ប្រាក់ និងដំណោះស្រាយទូទាត់ដោយស្វ័យប្រវត្តិ។

- **ការជ្រើសរើសដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់ត្រឹមត្រូវ៖**

នៅពេលជ្រើសរើសដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់ សូមពិចារណាលើកត្តាដូចជា មាត្រដ្ឋានភាពងាយស្រួលនៃការប្រើប្រាស់ និងការរួមបញ្ចូលជាមួយប្រព័ន្ធដែលមានស្រាប់។

- **ការអនុវត្តដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់៖**

ការអនុវត្តដោយជោគជ័យទាមទារការយល់ដឹងច្បាស់លាស់អំពីតម្រូវការអាជីវកម្មរបស់អ្នក និងវិធីសាស្ត្រដែលមានរចនាសម្ព័ន្ធដើម្បីផ្លាស់ប្តូរការគ្រប់គ្រង។

- **ការត្រួតពិនិត្យការអនុវត្តការគ្រប់គ្រងសាច់ប្រាក់៖**

ពិនិត្យជាប្រចាំនូវការអនុវត្តការគ្រប់គ្រងសាច់ប្រាក់ ដើម្បីកំណត់តំបន់សម្រាប់ការកែលម្អ និងធានាបាននូវសាច់ប្រាក់ងាយស្រួលបំផុត។

- **បញ្ហាប្រឈមក្នុងការគ្រប់គ្រងសាច់ប្រាក់៖**

អង្គការជាច្រើនប្រឈមមុខនឹងបញ្ហាក្នុងការគ្រប់គ្រងសាច់ប្រាក់ រួមទាំងការព្យាករណ៍មិនត្រឹមត្រូវ និងកង្វះទិន្នន័យតាមពេលវេលាជាក់ស្តែង។

- **អនាគតនៃដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់៖**

អនាគតនៃដំណោះស្រាយគ្រប់គ្រងសាច់ប្រាក់គឺកាន់តែឌីជីថល ដោយ AI និងស្វ័យប្រវត្តិកម្មដើរតួនាទីយ៉ាងសំខាន់។

**៣.២.២ ការវាយតម្លៃនៃការគ្រប់គ្រងសាច់ប្រាក់**

ការវាយតម្លៃនៃការគ្រប់គ្រងសាច់ប្រាក់ គឺជាដំណើរការដែលអាជីវកម្មប្រើប្រាស់ដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ខ្លួន។ វាជួយអាជីវកម្មក្នុងការកំណត់ថាតើមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ការប្រតិបត្តិការប្រចាំថ្ងៃ និងការបង់ប្រាក់ជំពាក់ឬទេ។

វិធីសាស្ត្រដែលអាជីវកម្មអាចប្រើប្រាស់សម្រាប់ការវាយតម្លៃនេះរួមមាន៖

ក. ការព្យាករណ៍លំហូរសាច់ប្រាក់៖ វាយតម្លៃលំហូរសាច់ប្រាក់ចូល និងចេញក្នុងអនាគត ដើម្បីធានាថាមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ការប្រតិបត្តិការប្រចាំថ្ងៃ។

ខ. ការវិភាគស្ថានភាពសាច់ប្រាក់បច្ចុប្បន្ន៖ ពិនិត្យសាច់ប្រាក់ដែលមានស្រាប់ និងប្រៀបធៀបវាជាមួយបំណុល និងការចំណាយដើម្បីវាយតម្លៃស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន។

គ. ការវិភាគសមត្ថភាពក្នុងការប្រមូលប្រាក់៖ វាយតម្លៃប្រសិទ្ធភាពក្នុងការប្រមូលប្រាក់ពីអតិថិជន និងការបង់ប្រាក់ពីអ្នកផ្គត់ផ្គង់ ដើម្បីធានាថាមានលំហូរសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ការប្រតិបត្តិការប្រចាំថ្ងៃ។

ឃ. ការវិភាគហានិភ័យហិរញ្ញវត្ថុ៖ វាយតម្លៃហានិភ័យដែលអាចប៉ះពាល់ដល់សាច់ប្រាក់ និងអនុវត្តយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។

ការវាយតម្លៃនេះអាចធ្វើបានតាមរយៈការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុដូចជា៖

- របាយការណ៍លំហូរសាច់ប្រាក់៖ បង្ហាញលំហូរសាច់ប្រាក់ចូល និងចេញក្នុងរយៈពេលជាក់លាក់។
- អត្រាប្រាក់សុទ្ធ៖ បង្ហាញអត្រាប្រាក់សុទ្ធដែលអាជីវកម្មទទួលបានពីការប្រមូលប្រាក់ និងការបង់ប្រាក់។
- ការវិភាគសមត្ថភាពក្នុងការប្រមូលប្រាក់៖ វាយតម្លៃប្រសិទ្ធភាពក្នុងការប្រមូលប្រាក់ពីអតិថិជន និងការបង់ប្រាក់ពីអ្នកផ្គត់ផ្គង់។

ការវាយតម្លៃនេះជួយអាជីវកម្មក្នុងការកំណត់ថាតើការគ្រប់គ្រងសាច់ប្រាក់របស់ខ្លួនមានប្រសិទ្ធភាពឬទេ និងត្រូវការកែប្រែអ្វីខ្លះដើម្បីធានាស្ថេរភាពហិរញ្ញវត្ថុ។ សម្រាប់ព័ត៌មានបន្ថែម អ្នកអាចអានអត្ថបទ "ការគ្រប់គ្រងសាច់ប្រាក់៖ គន្លឹះនៃស្ថិរភាពអាជីវកម្ម" ដែលបានបង្ហោះនៅលើគេហទំព័រ eMagia។

**៣.២.៣ តួនាទី និងភារៈនៃអ្នកគ្រប់គ្រង**

អ្នកគ្រប់គ្រងមានតួនាទីសំខាន់ក្នុងការដឹកនាំ និងគ្រប់គ្រងអង្គភាពឬស្ថាប័ន។ តួនាទីនិងភារៈរបស់អ្នកគ្រប់គ្រងអាចបែងចែកបានជា ៣ ប្រភេទសំខាន់ៗ៖

១. តួនាទីអន្តរៈបុគ្គល (Interpersonal Roles)

- អ្នកតំណាង (Figurehead)៖ តំណាងអង្គភាពក្នុងព្រឹត្តិការណ៍ផ្លូវការនិងសង្គម។
- អ្នកដឹកនាំ (Leader)៖ ដឹកនាំ និងបណ្តុះបណ្តាលបុគ្គលិក។
- អ្នកទំនាក់ទំនង (Liaison)៖ បង្កើត និងថែរក្សាទំនាក់ទំនងជាមួយអង្គភាពផ្សេងៗ។

២. តួនាទីព័ត៌មាន (Informational Roles)

• អ្នកប្រមូលព័ត៌មាន (Monitor)៖ តាមដានព័ត៌មានពីប្រភពខាងក្នុង និងខាងក្រៅ។

• អ្នកផ្សព្វផ្សាយ (Disseminator)៖ ចែករំលែកព័ត៌មានទៅកាន់បុគ្គលិក។

• អ្នកនាំពាក្យ (Spokesperson)៖ តំណាងអង្គភាពក្នុងការប្រាប់ព័ត៌មានទៅកាន់សាធារណៈ។

៣. តួនាទីធ្វើការសម្រេចចិត្ត (Decisional Roles)

• អ្នកសហគ្រិន (Entrepreneur)៖ ស្វែងរកឱកាសថ្មីៗ និងអភិវឌ្ឍន៍គម្រោងថ្មីៗ។

• អ្នកដោះស្រាយបញ្ហា (Disturbance Handler)៖ ដោះស្រាយបញ្ហាដែលកើតឡើងក្នុងអង្គភាព។

• អ្នកបែងចែកធនធាន (Resource Allocator)៖ ចាត់ចែងធនធានដូចជា ពេលវេលា និងថវិកា។

• អ្នកចរចារ (Negotiator)៖ ចរចារកិច្ចព្រមព្រៀងជាមួយភាគីផ្សេងៗ។

តួនាទីទាំងនេះត្រូវបានបង្ហាញក្នុងការសិក្សារបស់ Mintzberg ដែលបានបែងចែកតួនាទីរបស់អ្នកគ្រប់គ្រងជាបីប្រភេទសំខាន់ៗ។

## ៣.៣ ផលប៉ះពាល់លើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុនជីប ម៉ុង

ការគ្រប់គ្រងសាច់ប្រាក់ (liquidity management) មានសារៈសំខាន់ណាស់សម្រាប់ប្រសិទ្ធភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន Chip Mong និងក្រុមហ៊ុនផ្សេងទៀត។ ខាងក្រោមជាការវិភាគលម្អិតអំពីផលប៉ះពាល់ចម្បងលើប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់រួមមាន៖

**១.សេដ្ឋកិច្ចក្នុងក្រុមហ៊ុន៖** បន្ថយការខ្វះសាច់ប្រាក់, ជៀសវាង និងការទូទាត់យឺត

**២. សេដ្ឋកិច្ចជាតិ៖** បង្កើនស្ថិរភាពហិរញ្ញវត្ថុ, ជួយបង្កើនជំនឿអ្នកវិនិយោគ

**៣.បច្ចេកវិទ្យា៖** អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាទំនើប

**៤. សង្គម៖** បង្កើនភាពជឿជាក់លើប្រព័ន្ធហិរញ្ញវត្ថុ, បង្កើតការងារ។

### ៣.៣.១ ការគ្រប់គ្រងសាច់ប្រាក់កុំឱ្យមានផលប៉ះពាល់

ការគ្រប់គ្រងសាច់ប្រាក់កុំឱ្យមានផលប៉ះពាល់ ម្ចាស់អាជីវកម្មគួរតែ តាមដានទាំងស្រុងទៅលើលំហូរសាច់ប្រាក់ចូល និងចេញ។ លើសពីនេះទៅទៀតត្រូវចងចាំដែរថា ប្រសិនបើក្រុមហ៊ុនរបស់អ្នកអស់សាច់ប្រាក់នោះអាជីវកម្មនឹងត្រូវប្រឈមមុខនឹងហានិភ័យក្ស័យធនផងដែរ។ ដូច្នេះ យើងគួរតែកុំមើលរំលងអំពីការគ្រប់គ្រងលំហូរសាច់ប្រាក់ ពីព្រោះលំហូរសាច់ប្រាក់ក៏អាចមានផលប៉ះពាល់ដល់តម្លៃផលិតផល ការទូទាត់របស់អតិថិជន សំណងដល់បុគ្គលិក និងជាច្រើនទៀត។ ដើម្បីទប់ស្កាត់កុំឱ្យមានផលប៉ះពាល់ទៅលើសាច់ប្រាក់ក្រុមហ៊ុនត្រូវពិនិត្យរាល់ចំណូលនឹងចំណាយឱ្យទាងទាត់ជាប្រចាំ។

**យុទ្ធសាស្ត្របង្កើនប្រសិទ្ធភាព**

• ការព្យាករណ៍ និងរៀបចំ Cash flow៖ កំណត់ចំនួនទឹកប្រាក់កំពុងចេញចូលក្នុងអនាគត ដើម្បីសម្របខ្លួន និងជៀសវាង liquidity gap

• ផ្សារភាគខ្ទង់សាច់ប្រាក់បណ្តោះអាសន្ន (Diversifying funding sources)៖ ពង្រីកទ្រព្យសម្បត្តិនៅក្នុងទីផ្សារផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យ ។

• Stress testing និង scenario analysis៖ វាយតម្លៃហានិភ័យ liquidity ក្នុងករណីវិបត្តិ (ដកប្រាក់ជ្រុលនៃឧស្សាហកម្ម)។

• រៀបចំ ត្រួតពិនិត្យរបាយការណ៍គ្រប់គ្រងសាចប្រាក់ប្រចាំថ្ងៃ៖ ត្រួតពិនិត្យរាល់ចំណូលចំណាយធៀបជាមួយផែនការសាច់ប្រាក់ឱ្យបានត្រឹមត្រូវ។

**ក- ការគ្រប់គ្រងចំណូលនៃការលក់របស់ក្រុមហ៊ុនជីបម៉ុង**

សម្រាប់ចំណូលនៃការលក់របស់ក្រុមហ៊ុន ជីបម៉ុង របស់ផ្សារទំនើប 271 មិនអាចផ្តល់ព័ត៌មានលម្អិតអំពីចំណូលនៃការលក់របស់ក្រុមហ៊ុននៅពេលបច្ចុប្បន្នបានទេ។ ទោះយ៉ាងណាយើងសង្កេតឃើញព័ត៌មានទាក់ទងនឹងការវិនិយោគ និងការចំណាយដ៏ធំនៅលើគម្រោងនេះ៖

➢ **ការវិនិយោគក្នុងការសាងសង់ និងបញ្ចប់គម្រោង**

Chip Mong Retail បានវិនិយោគជាច្រើនលើគម្រោង 271 Mega Mall ត្រូវបានវិនិយោគសាងសង់ផ្នែកមួយក្នុងគម្រោង Retail ខ្នាតធំរហូតដល់ **US$240-252**លាន សម្រាប់អគារផ្សារ ៥ ជាន់ និងគ្រោងទុកសាធារណៈ។

➢ **ចំណូលពីភាគីសាងសង់( ពាក់ព័ន្ធ Chip Mong271 )**

នៅ Q2 FY 2023 ទិន្នន័យរបាយការណ៍ DBD Engineering បង្ហាញថា "Revenuse from maintenance and construction" មានចំនួន **KHR28,588,920,000**(~**$7.1**លាន ) * *,ដែលប្រហែល 99.8% នៃចំណូលសរុប2023។

ចំណូលសរុបរបស់ Q3 FY 2023 សម្រាប់ "maintenance and construction"គឺ **KHR18,339,593,000** (~**$4.6**លាន ) * *,សម្រាប់ 3 ខែជាងមុន។

**ខ-ការរៀបចំគម្រោងចំណាយសាច់ប្រាក់របស់ក្រុមហ៊ុនជីបម៉ុង**

ការរៀបចំគម្រោងចំណាយសាច់ប្រាក់សម្រាប់ក្រុមហ៊ុនជីបម៉ុង គឺជាដំណើរការសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធានាថាក្រុមហ៊ុនអាចដំណើរការបានយ៉ាងមានប្រសិទ្ធភាពនាពេលខាងមុខ។ ដើម្បីរៀបចំគម្រោងចំណាយសាច់ប្រាក់ អ្នកអាចអនុវត្តវិធីសាស្ត្រដូចខាងក្រោម៖

1. **កំណត់គោលបំណង និងគម្រោង៖** កំណត់គោលបំណងរបស់គម្រោង និងសកម្មភាពដែលត្រូវអនុវត្តដើម្បីសម្រេចគោលបំណងនោះ។

2. **វាយតម្លៃធនធានដែលមាន៖** ពិនិត្យមើលធនធានហិរញ្ញវត្ថុដែលក្រុមហ៊ុនមានដូចជា ចំណូលនឹងប្រាក់ចំណេញ ដើម្បីកំណត់ថវិកាដែលអាចចំណាយបាន។

3. **បែងចែកថវិកាតាមផ្នែក៖** បែងចែកថវិកាទៅតាមផ្នែកនីមួយៗ ដូចជា ផ្នែកទីផ្សារ ផ្នែកផលិតកម្ម ផ្នែកសេវាកម្ម និងផ្នែកផ្សេងៗ ដើម្បីធានាថាការចំណាយត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព។

4. **កំណត់ចំណាយប្រចាំខែ៖** កំណត់ចំណាយប្រចាំខែសម្រាប់សកម្មភាពនីមួយៗ ដើម្បីធានាថាការចំណាយមិនលើសថវិកា។

5. **តាមដាន និងវាយតម្លៃ៖** តាមដានការចំណាយជាក់ស្តែង និងប្រៀបធៀបជាមួយថវិកា ដើម្បីវាយតម្លៃប្រសិទ្ធភាព និងធ្វើការកែប្រែប្រសើរប្រសិនបើចាំបាច់។

**៣.៣.២ ការទប់ស្កាត់លើផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង**

ការគ្រប់គ្រងសាច់ប្រាក់បង្កាហានិភ័យ (Risk-Based Capital Management) គឺជាការប្រើប្រាស់ការវិភាគនិងយុទ្ធសាស្ត្រផ្សេងៗក្នុងការកំណត់ការប្រើប្រាស់ធនធានប្រាក់ដោយសមស្របនឹងកម្រិតនៃការ

ប្រឈមមុខនឹងហានិភ័យ។ វាជាការអនុវត្តន៍សម្រាប់ត្រួតពិនិត្យនិងបង្រ្កាបហានិភ័យស្តីពីវិធីដែលស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់សាច់ប្រាក់ដើម្បីផ្គូផ្គងជាមួយនឹងហានិភ័យដែលមាននៅក្នុងប្រព័ន្ធ។

ការគ្រប់គ្រងនេះ អាចជួយធានាថាស្ថាប័នហិរញ្ញវត្ថុមានសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីបញ្ចេញការប្រឈមមុខនឹងហានិភ័យផ្សេងៗដូចជាៈ

1. **ហានិភ័យការបាត់បង់**: ឧបករណ៍ផ្ទាំងធនធានសាច់ប្រាក់អាចត្រូវប្រើសម្រាប់ដោះសោការប្រឈមនៃការបាត់បង់ទ្រព្យសម្បត្តិដែលអាចកើតឡើងពីហានិភ័យសេដ្ឋកិច្ច។

2. **ហានិភ័យសកល**: ប្រព័ន្ធវិនិយោគដែលមានហានិភ័យនៅលើការផ្លាស់ប្តូរប្រាក់ចំណេញ ឬតម្លៃផ្សេងៗ។

3. **ហានិភ័យនៃការបញ្ឆោល**: ការវិនិយោគដែលអាចបង្កើតហានិភ័យនៃការបញ្ឆោលទៅក្នុងទីផ្សារហិរញ្ញវត្ថុ។

**៣.៣.៣ គ្រប់គ្រង អតិថិជនឱ្យមានស្ថិរភាព**

ការបាត់បង់ហិរញ្ញវត្ថុ គឺជាការបាត់បង់ប្រាក់ ដែលមានតម្លៃ ដោយសារតែហេតុផលផ្សេងៗ។ ការបាត់បង់នេះអាចកើតឡើងក្នុងគ្រួសារដោយសារកំហុសក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ដូចជាៈ

1. **គ្មានផែនការហិរញ្ញវត្ថុច្បាស់លាស់ៈ** គ្រួសារមិនមានផែនការច្បាស់លាស់សម្រាប់ការចំណាយ និងការសន្សំ។

2. **គ្មានប្រាក់បម្រុងសម្រាប់គ្រោះអាសន្នៈ** គ្រួសារមិនមានប្រាក់បម្រុងសម្រាប់គ្រោះអាសន្ន។

3. **គ្មានការឯកភាពលើទម្លាប់ចំណាយ និងផែនការចំណាយៈ** គ្រួសារមិនមានការឯកភាពលើទម្លាប់ចំណាយ និងផែនការចំណាយ។

4. **មិនបានបែងចែកទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុរវាងប្តី និងប្រពន្ធៈ** គ្រួសារមិនបានបែងចែកទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុរវាងប្តី និងប្រពន្ធ។ ដើម្បីជៀសវាងការបាត់បង់ហិរញ្ញវត្ថុ គ្រួសារត្រូវតែមានផែនការហិរញ្ញវត្ថុច្បាស់លាស់ និងការបែងចែកទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុយ៉ាងត្រឹមត្រូវ។

**៣.៣.៤ ការត្រួតពិនិត្យលើការបាត់បង់**

ការត្រួតពិនិត្យវាទាក់ទងទៅនឹងការវាយតម្លៃ ឬវិនិច្ឆ័យប្រកបដោយជោគជ័យ នៃការឈានទៅសម្រេចគោលដៅ ហើយបន្ទាប់មកធ្វើការកែសម្រួលនូវសកម្មភាពខ្លះៗប្រសិនបើចាំបាច់នៅពេលដែលគោលដៅមិនអាចសម្រេចបាន។ បន្ទាប់ពីឆ្លងកាត់ដំណាក់កាលនៃការត្រួតពិនិត្យគេអាចមានលទ្ធភាពឃើញហេតុអ្វីបានជាគោលដៅរបស់អង្គភាពមិនបានសម្រេច ព្រមជាមួយនោះ គេអាចធ្វើការកែសម្រួលតាមជំហានៗនៃដំណើរការអនុវត្តសកម្មភាព។ ក្នុងដំណាក់កាលនៃការត្រួតពិនិត្យ ត្រូវបានគេចែកចេញជាបីជំហានខុសៗគ្នា

**ក. វាស់ ឬប៉ាន់ស្មានការអនុវត្តជាក់ស្តែងៈ** ជាញឹកញាប់អ្នកគ្រប់គ្រងប្រើ ដើម្បីវាស់ការអនុវត្តន៍ជាក់ស្តែង ការសង្កេតដោយផ្ទាល់ របាយការណ៍ស្ថិតិ របាយការណ៍ផ្ទាល់មាត់ របាយការណ៍សរសេរ។

**ខ. ការប្រៀបធៀបៈ** ការកំណត់នូវកម្រិតប្រែប្រួលរវាងការអនុវត្តន៍ជាក់ស្តែង ជាមួយផែនការដែលបានកំណត់។

**គ. អនុវត្តនូវសកម្មភាពគ្រប់គ្រងៈ** អ្នកគ្រប់គ្រងត្រួតពិនិត្យមើល បើមានកន្លែងខ្វះខាត ត្រូវជំរុញផ្នែកនិងឱ្យខ្លាំង។

**៣.៣.៥ ការបាត់បង់ហិរញ្ញវត្ថុ**

វាជារឿងធម្មតាទេដែលប្រឈមនឹងហានិភ័យនៅក្នុងសកម្មភាពណាមួយហើយការគ្រប់គ្រងហានិភ័យល្អគឺជាកត្តាសំខាន់ក្នុងដំណើរការប្រតិបត្តិការដោយជោគជ័យ។ រាល់ការគ្រប់គ្រងមានកំរិតគ្រប់គ្រង ផ្សេងៗគ្នាទាក់ទងនឹងហានិភ័យ។ ហានិភ័យមួយចំនួនអាចត្រូវបានគ្រប់គ្រងដោយផ្ទាល់ប៉ុន្តែហានិភ័យមួយចំនួនធំលើសការគ្រប់គ្រង។ អ្វីដែលល្អបំផុតដែលសហគ្រាសអាចធ្វើបានគឺការប្រមើលមើលហានិភ័យដែលអាចកើតមានគ្រប់គ្រងហានិភ័យដែលអាចនឹងជះឥទ្ធិពលដល់ប្រតិបត្តិការឱ្យបានត្រឹមត្រូវវាយតម្លៃផលប៉ះពាល់របស់ពួកគេឱ្យបានត្រឹមត្រូវហើយព្យាយាមត្រៀមប្រតិកម្មឱ្យបានត្រឹមត្រូវក្នុងស្ថានភាពគ្រោះថ្នាក់។ វិធីសាស្ត្រ គឺត្រូវបែងចែកហានិភ័យហិរញ្ញវត្ថុជា ៤ ប្រភេទធំៗ គឺ

- ហានិភ័យទីផ្សារ ត្រូវបានជួបប្រទះនៅពេលមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងទីផ្សារដែលក្រុមហ៊ុនមួយប្រកួតប្រជែង។
- ហានិភ័យឥណទាន គឺជាហានិភ័យដែលអាជីវកម្មនឹងចេញបន្ទាត់ឥណទានដល់អតិថិជនរបស់ពួកគេឬអាជីវកម្មមិនមានថវិកាគ្រប់គ្រាន់ដើម្បីទូទាត់។
- ហានិភ័យសាច់ប្រាក់ សំដៅទៅលើភាពងាយស្រួលនៃសហគ្រាសមួយដែលអាចបំលែងទ្រព្យសម្បត្តិរបស់ខ្លួនទៅជាសាច់ប្រាក់បានប្រសិនបើវាត្រូវការមូលនិធិ។ វាក៏សំដៅទៅលើលំហូរសាច់ប្រាក់ប្រចាំថ្ងៃផងដែរ។
- ហានិភ័យប្រតិបត្តិការ កើតឡើងដោយសារសកម្មភាពអាជីវកម្មជាទៀងទាត់របស់សហគ្រាសនិងរាប់បញ្ចូលទាំងការបន្លំបណ្តឹងនិងបញ្ហានិយោជិក។

**៣.៣.៦ ការកាត់បន្ថយហានិភ័យផ្ទៃក្នុង**

ការគ្រប់គ្រងហានិភ័យផ្ទៃក្នុង គឺជាដំណើរការនៃការកាត់បន្ថយជាអប្បបរមា ឬការបន្ធូរបន្ថយហានិភ័យអវិជ្ជមាននៃហានិភ័យ និងទាញយកផលប្រយោជន៍ពីឱកាសវិជ្ជមាន។ វាចាប់ផ្តើមជាមួយនឹងការកំណត់ អត្តសញ្ញាណ និងការវាយតម្លៃហានិភ័យ បន្ទាប់មកប្រើធនធានល្អបំផុតដើម្បីគ្រប់គ្រងតាមដាននិងកាត់បន្ថយជាអប្បបរមានូវហានិភ័យ។ ព្រឹត្តិការណ៍ឬហានិភ័យដែលមានភាពទំនងជាកើតឡើងខ្ពស់ហើយផលប៉ះពាល់គឺកាន់តែខ្លាំង តម្រូវឱ្យមានការគ្រប់គ្រងកាន់តែទូលំទូលាយ។ នេះគឺជារបៀបដែលអាទិភាពជាក់លាក់អាចត្រូវបានបង្កើតឡើងក្នុងការដោះស្រាយ និងគ្រប់គ្រងហានិភ័យ។ ការគ្រប់គ្រងហានិភ័យតែងតែជាដំណើរការបន្ត ជាយុទ្ធសាស្ត្រវនិងស្វាហាប់ដែលហានិភ័យ និងប្រព័ន្ធគ្រប់គ្រងហានិភ័យត្រូវបានត្រួតពិនិត្យនិងវាយតម្លៃឡើងវិញជាមួយនឹងលទ្ធផលដែលបានអនុវត្តនៅក្នុងប្រព័ន្ធគ្រប់គ្រងសម្រាប់ការវាយតម្លៃនិងការត្រួតពិនិត្យបន្ថែមទៀត។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវរួចមក ក្រុមរបស់យើងខ្ញុំទទួលបាននូវព័ត៌មានដោយផ្អែកទៅលើទ្រឹស្តី និងលទ្ធផលជាក់ស្តែង អាចធ្វើការវិភាគអំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ក្រុមហ៊ុន ជីបម៉ុងដូចខាងក្រោម៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ក្រុមហ៊ុនមានយុទ្ធសាស្ត្រទីផ្សារខ្លាំងលើគ្រប់វិស័យ ដែលបត់បែនទៅតាមភាពចម្រុះរបស់អតិថិជនជាមួយនឹងការផ្តល់ជូននូវអត្ថប្រយោជន៍ និងការផ្តល់ជូនពិសេស។
- ផ្តល់សេវាផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ ហើយមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រង់សាច់ប្រាក់សម្រាប់អតិថិជន និងផ្នែកទិញលក់។
- គ្រប់គ្រងហានិភ័យ កាត់បន្ថយជាអប្បបរមា ឬការបន្ធូរបន្ថយហានិភ័យអវិជ្ជមាន និងទាញយកផលប្រយោជន៍ពីឱកាសវិជ្ជមាន។
- ការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុននេះចូលរួមដំណើរការជាមួយបច្ចេកវិទ្យាថ្មីៗ ដូចជាបច្ចេកវិទ្យាថ្មីក្នុងការពិចារណាអំពីជំនួញ និងសកម្មភាពហិរញ្ញវត្ថុផ្សេងៗ។
- ការវិភាគហានិភ័យហិរញ្ញវត្ថុ វាយតម្លៃលើហានិភ័យដែលអាចប៉ះពាល់ដល់សាច់ប្រាក់ និងការអនុវត្តយុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។
- ក្រុមហ៊ុនបានវិនិយោគក្នុងបច្ចេកវិទ្យាទំនើប ដើម្បីផ្តល់សេវាឌីជីថលលំដាប់ពិភពលោក និងផលិតផលហិរញ្ញវត្ថុថ្មីៗ ស្របតាមតម្រូវការ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ក្រុមហ៊ុនជីបម៉ុង ក៏ដូចជាក្រុមហ៊ុនពាណិជ្ជកម្មផ្សេងទៀត តែងតែមានចំណុចខ្វះខាតផ្សេងៗ ដែលអាចរារាំងភាពជោគជ័យ និងភាពរីកចម្រើនរបស់ក្រុមហ៊ុន។ ភាពទន់ខ្សោយឬភាពខ្វះខាតទាំងនេះ អាចកើតឡើងពីកត្តាខាងក្នុងក្រុមហ៊ុនឬកត្តាខាងក្រៅនៅក្នុងវិស័យពាណិជ្ជកម្ម។ ក្រុមហ៊ុន ជីបម៉ុង អាចប្រឈមហានិភ័យដូចខាងក្រោម៖

- ក្រុមហ៊ុនខ្វះការគ្រប់គ្រងផ្នែកធនធានមនុស្ស ក្នុងការអនុវត្តន៍អាជីវកម្ម
- ប្រឈមមុខនឹងបញ្ហាក្នុងការគ្រប់គ្រងសាច់ប្រាក់ រួមទាំងការព្យាករណ៍មិនត្រឹមត្រូវ និងកង្វះទិន្នន័យតាមពេលវេលាជាក់ស្តែង។
- ការប្រើប្រាស់ចំណាយលើសពីគម្រោងផែនការដែរបានគ្រោងទុកជាមុន។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងទៅតាមការបកស្រាយបំភ្លឺ ទៅលើចំណុចជាច្រើនទាក់ទងទៅលើប្រធានបទស្តីពី " **ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ជីបម៉ុង** " កន្លងមកក្រោមការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់គ្រូដឹកនាំនៃសាកលវិទ្យាល័យ វ៉ាន់ដា បានជួយពន្យល់ណែនាំ បង្ហាញពីប្រភពព័ត៌មាន និងកែតម្រូវនូវចំណុចខ្វះខាត គួបផ្សំនឹងចំណេះដឹងដែលបានសិក្សាកន្លងមក ធ្វើឱ្យខ្ញុំបានសម្រេចកិច្ចការស្រាវជ្រាវប្រធានបទមួយនេះបានដោយជោគជ័យ។

តាមរយៈការស្រាវជ្រាវរួចមកអំពី ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ អាចសន្និដ្ឋានបានថា ក្រុមហ៊ុន ជីបម៉ុង បានបោះជំហានយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ដែលបញ្ជាក់ពីភាពខ្លាំងនឹងភាពរឹងមាំក្នុងការផ្តល់ទំនុកចិត្តជូនដល់អតិថិជន។ ក្រុមហ៊ុនបានវិនិយោគក្នុងបច្ចេកវិទ្យាទំនើប ដើម្បីផ្តល់សេវាឌីជីថលលំដាប់ពិភពលោក និងផលិតផលហិរញ្ញវត្ថុថ្មីៗ ស្របតាមតម្រូវការ។

ជីបម៉ុងជាក្រុមហ៊ុនដែលមានយុទ្ធសាស្ត្រទីផ្សារខ្លាំងលើគ្រប់វិស័យ ដែលបត់បែនទៅតាមភាពចម្រុះរបស់អតិថិជន ជាមួយនឹងការផ្តល់ជូននូវអត្ថប្រយោជន៍ និងការផ្តល់ជូនពិសេស។ ហើយយុទ្ធសាស្ត្រទីផ្សាររបស់ក្រុមហ៊ុនទាំងនោះរួមមាន៖ ការបែងចែកទីផ្សារតាម អតិថិជនមានតម្រូវការផ្សេងៗគ្នា ហេតុនេះហើយបានក្រុមហ៊ុមបង្កើតផលិតផលនិងសេវាកម្មសមរម្យសម្រាប់គ្រប់តម្រូវការ (ដូចជា ផ្ទះលំនៅគ្រប់ថ្នាក់, ផលិតផលសំណង់គុណភាពខ្ពស់, សេវាផ្សារទំនើបជាច្រើនលំដាប់)។ ការផ្តល់ជូននូវអត្ថប្រយោជន៍និងពិសេសភាពជីបម៉ុងប្រើប្រាស់ជាច្រើនកន្លែងដើម្បីទាក់ទាញអតិថិជន ដូចជា ការបញ្ចុះតម្លៃពិសេស, ការប្រមូលពិន្ទុសម្រាប់ប្តូរលើកក្រោយ, ឬកម្មវិធីសមាជិក។ ការបត់បែនតាមការផ្លាស់ប្តូរទីផ្សារ ក្រុមហ៊ុនមានភាពធ្វើអោយអាជីវកម្មសមស្របទៅនឹងបែបបទថ្មីៗ ដូចជា ការលក់តាមអនឡាញ ការផ្តោតលើបទពិសោធន៍អតិថិជន និងការចូលរួមជាមួយសហគមន៍។ ផ្តល់សេវាផ្នែកហិរញ្ញវត្ថុគ្រប់ប្រភេទ ហើយមានប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសាច់ប្រាក់សម្រាប់អតិថិជន និងផ្នែកទិញលក់។ ការវិភាគហានិភ័យហិរញ្ញវត្ថុ វាយតម្លៃលើហានិភ័យដែលអាចប៉ះពាល់ដល់សាច់ប្រាក់ និងការអនុវត្តន៍យុទ្ធសាស្ត្រដើម្បីកាត់បន្ថយហានិភ័យទាំងនោះ។ សរុបគឺ ជីបម៉ុងមិនត្រឹមតែជាក្រុមហ៊ុនមួយប៉ុណ្ណោះទេ ប៉ុន្តែជាក្រុមហ៊ុនដែលមាន ទស្សនៈវិស័យច្បាស់លាស់ក្នុងការច្នៃប្រឌិត និងបំផុសអាជីវកម្មជាច្រើន ដោយផ្អែកលើតម្រូវការពិតប្រាកដនៃទីផ្សារកម្ពុជា។

## ៥.២ អនុសាសន៍

បន្ទាប់ពីបានធ្វើការសន្និដ្ឋាន និងការស្រាវជ្រាវកន្លងមករបស់ក្រុមហ៊ុន ជីបម៉ុង រួចមកបានបង្ហាញឱ្យឃើញថា ក្រុមហ៊ុនបានផ្តល់នូវភាពជឿជាក់ដល់អតិថិជនទាំងក្នុងប្រទេស និងអន្តរជាតិ នូវការគ្រប់គ្រងសាច់ប្រាក់ដែលបានចូលរួមចំណែក នៃការអភិវឌ្ឍន៍សេដ្ឋកិច្ចមួយកម្រិតផងដែរខាងវិស័យពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះផងដែល ក្រុមហ៊ុន ជីបម៉ុង ក៏មានចំណុចខ្វះខាតមួយចំនួន ដើម្បីជួយឱ្យចំណុចខ្វះខាតខាងលើរបស់ក្រុមហ៊ុនកាន់តែប្រសើរឡើង ក្រុមរបស់យើងខ្ញុំសូមផ្តល់ជាអនុសាសន៍លើចំណុចដូចខាងក្រោម៖

- ក្រុមហ៊ុនខ្វះការគ្រប់គ្រងផ្នែកធនធានមនុស្ស ក្នុងការអនុវត្តន៍អាជីវកម្ម ដូច្នេះត្រូវធ្វើការបណ្តុះបណ្តាលបន្ថែមទៅលើការអនុវត្តន៍ជាក់ស្តែងទាំងផ្នែកខាងក្រៅ និងផ្នែកខាងក្នុង។
- ប្រឈមមុខនឹងបញ្ហាក្នុងការគ្រប់គ្រងសាច់ប្រាក់ រួមទាំងការព្យាករណ៍មិនត្រឹមត្រូវ និងកង្វះទិន្នន័យតាមពេលវេលាជាក់ស្តែង។

សរុបមកការឱ្យអនុសាសន៍ខាងលើនេះ វាគ្រាន់ជាផ្នែកតូចមួយដែលក្រុមនាងខ្ញុំគិតថាជាចំណុចខ្វះខាតក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន។ ប្រសិនបើក្រុមរបស់យើងខ្ញុំបានរៀបរាប់ពីចំណុចខ្វះខាតរបស់ក្រុមហ៊ុន និងបានធ្វើការផ្តល់ជាអនុសាសន៍មួយចំនួនដែលបានរៀបរាប់ដូចខាងលើ ប្រសិនបើមានចំណុចលើសលុប ឬមានកំហុសឆ្គងត្រង់ណានោះក្រុមរបស់យើងខ្ញុំ សូមធ្វើការអភ័យទោសដល់ក្រុមហ៊ុនទុកជាមុនផង រាល់ការលើកឡើងខាងលើនេះ។

# ឯកសារយោង (References)


1. ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ. (2024, May). *ប្រវត្តិនៃការគ្រប់គ្រងសាច់ប្រាក់.* ទំព័រទី៨. Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/04/ឧត្តមានុវត្តន៍នៃការគ្រប់គ្រងហិរញ្ញវត្ថុ_22.pdf
2. បរៀងដោយ ប៊ុល កុសល. ដំណើរការវិវត្តនៃការគ្រប់គ្រងរដ្ឋបាលសាធារៈនៅកម្ពុជា ឆ្នាំ១៩៩៣-២០០៣ . *ប្រវត្តិនៃការគ្រប់គ្រង"មានន័យដូចម្ដេច"* ទំព័រទី១៥-៥៩។ Retrieved from
3. https://www.ebooks.libraryrac.com/public/images/files/161163555
4. WordPress. មិត្តនិស្សិត. (2011, May 31). *និយមន័យពាក្យគ្រប់គ្រង* Retrieved from https://clubniset.wordpress.com/2011/05/31/និយមន័យនៃការគ្រប់គ្រង/
5. Khsearch. ហ៊ូ សម្ផស្ស. (2018, Setember 21). *ដូចម្ដេចហៅថាការគ្រប់គ្រង?* Retrieved from https://www.khsearch.com/qna/7930
6. Investopedia. (2024, September 23). *ផលប៉ះពាល់នៃការគ្រប់គ្រងសាច់ប្រាក់.* Retrieved from https://www.investopedia.com/terms/c/cash-management.asp
7. KHsearch. ចំណេះដឹងទូទៅ. (2018, September 27). *តួនាទីនៃអ្នកគ្រប់គ្រងមានអ្វីខ្លះ?* Retrieved from http://www.khsearch.com/qna/8189
8. KHsearch. ចំណេះដឹងទូទៅ. (2018, September 27). *មុខនៃការគ្រប់គ្រងមានអ្វីខ្លះ?* Retrieved from http://www.khsearch.com/qna/8186

# ឧបសម្ព័ន្ធ

## ១. សមាជិកក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ជីបម៉ុង




## ២. ផ្សារទំនើប ជីបម៉ុង 271




ផ្សារទំនើប
CHIP MONG 271
MEGA MALL
CHIPMONG 271 MEGAMALL


ពិធីបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់ ផ្សារទំនើប
ជីប ម៉ុង ២៧១ មេហ្គាម៉ល
CHIP MONG RETAIL


CHIP MONG
271 MEGAMALL
អបអរការបើកដំណើរការ សាកល្បង
ផ្សារទំនើប ជីប ម៉ុង ២៧១ មេហ្គា ម៉ល
12 កញ្ញា 2022
SOFT OPENING


SAMRITH


SKECHERS
adidas
ONE
BEYOND


AKEMI
OPENING
SAMRITH


SAMRITH


Ora
LACOSTE
MEGA ONE YEAR